ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការវាយតម្លៃការសិក្សាកម្រិតថ្នាក់រៀនៈ ទស្សនៈ ការប្រើប្រាស់  និងយុទ្ធសាស្ត្ររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ធំ

# CLASSROOM ASSESSMENT: Perception, Use and Strategy of Upper Secondary  School Teacher in Kompong Thum Province

ដោយ/by

អុន សេងទ្រី

ON SENGTRY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៦

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០១៧ ‑ ២០១៨

ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការវាយតម្លៃការសិក្សាកម្រិតថ្នាក់រៀន៖ ទស្សនៈ ការប្រើប្រាស់ និងយុទ្ធសាស្ត្ររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ធំ

CLASSROOM ASSESSMENT:

Perception, Use and Strategy of Upper Secondary School Teacher

in Kompong Thum Province

**ដោយ**/by

**អុន សេងទ្រី**

ON SENGTRY

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៥**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា២០១៦ - ២០១៨**

សាស្ត្រាចារ្យដឹកនាំ៖ **បណ្ឌិត ម៉ុក សារ៉ុម**

សាស្ត្រាចារ្យដឹកនាំរង៖ **សាំង សុចិន្តា**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation (CIESF)

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ការវាយតម្លៃការសិក្សាកម្រិតថ្នាក់រៀនៈ ទស្សនៈ ការប្រើប្រាស់ និងយុទ្ធសាស្រ្តរបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ធំ** " សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានអប់រំ គឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បាន ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទ ស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ.............................ខែ...........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ...............ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

ការបញ្ជាក់ពីសាស្រ្តាចារ្យដឹកនាំ

ក្នុងនាមជាសាស្រ្តាចារ្យដឹកនាំការសរសេរនិក្ខេបបទស្រាវជ្រាវនេះ

សូមបញ្ជាក់ថាបេក្ខជន **អុន សេងទ្រី**

ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវពិតប្រាកដមែន។

ថ្ងៃ ...............................ខែ.................ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី.................ខែ..................ឆ្នាំ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និង អង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) Cambodia International Education Support Foundation ដែលបានរៀបចំ និងផ្តល់អាហាររូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកសាស្ត្រាចារ្យ **បណ្ឌិត ម៉ុក សារ៉ុម** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហាន ទើបធ្វើឱ្យការស្រាជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកស្រីសាស្ត្រាចារ្យជំនួយ **សាំង សុចិន្តា** និងមិត្តរួមជំនាន់ទី៥ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្ត តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឱ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀតខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកឪពុក អ្នកម្តាយ និងបងប្អូនខ្ញុំបាទ ដែលបានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឱ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធិពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងភរិយាខ្ញុំបាទឱ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន .................... i

សេចក្តីថ្លែងអំណរគុណ .................... ii

មាតិកា .................... iii

តារាង .................... vi

រូបភាព .................... vii

មូលន័យសង្ខេប .................... viii

ជំពូកទី១ .................... 1

សេចក្តីផ្តើម .................... 1

១.១ សាវតារនៃការស្រាវជ្រាវ .................... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ .................... 2

១.៣ គោលបំណងនៃការស្រាវជ្រាវ .................... 3

១.៤ សំណួរស្រាវជ្រាវ .................... 4

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ .................... 4

១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ .................... 4

ជំពូក២ .................... 5

រំឭកទ្រឹស្តី .................... 5

២.១ និយមន័យពាក្យគន្លឹះ .................... 5

២.២ គោលនយោបាយពាក់ព័ន្ធនឹងការវាយតម្លៃ .................... 5

២.៣ ប្រភេទនៃការវាយតម្លៃ .................... 7

២.៤ ក្របខណ្ឌរបស់ការសិក្សានេះ .................... 9

២.៥ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន .................... 10

២.៦ យុទ្ធសាស្រ្តក្នុងការវាយតម្លៃ .................... 11

ជំពូក៣ .................... 13

វិធីសាស្ត្រស្រាវជ្រាវ ........ 13
៣.១ ការរៀបចំការស្រាវជ្រាវ ........ 13
៣.២ ប្រជាករ (Population) និងសំណាកស្រាវជ្រាវ (Sample) ........ 13
៣.២.១ ប្រជាករ(Population) ........ 13
៣.២.២ សំណាកស្រាវជ្រាវ (Sample) ........ 14
៣.២.៣ លក្ខណៈទូទៅរបស់អ្នកចូលរួម ........ 15
៣.៤ ឧបករណ៍ស្រាវជ្រាវ ........ 19
    ៣.៤.១ កម្រងសំណួរស្តីពីការវាយតម្លៃកម្រិតថ្នាក់រៀន ........ 20
    ៣.៤.២ ប្រសិទ្ធភាពនៃឧបករណ៍ស្រាវជ្រាវ ........ 20
៣.៥ ដំណើរការប្រមូលទិន្នន័យ ........ 20
៣.៦ ការគ្រប់គ្រង និងវិភាគទិន្នន័យ ........ 21
ជំពូក៤ ........ 22
លទ្ធផលការស្រាវជ្រាវ ........ 22
៤.១. លទ្ធផលសិក្សាស្រាវជ្រាវបណ្តុំទី១៖ ទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀន ........ 22
៤.២. បណ្តុំទី២៖ យុទ្ធសាស្ត្រនៃការអនុវត្តការវាយតម្លៃកម្រិតថ្នាក់រៀន ........ 25
៤.៣. បណ្តុំទី៣៖ ការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន ........ 32
ជំពូក៥ ........ 36
សរុបលទ្ធផល ការពិភាក្សា និងអនុសាសន៍ ........ 36
៥.១ សេចក្តីសន្និដ្ឋាន ........ 37
៥.២ អនុសាសន៍ ........ 39
    ៥.២.១ អនុសាសន៍សម្រាប់ការអនុវត្ត ........ 39
    ៥.២.១ អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត ........ 39
ឯកសារយោង ........ 41
ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា ........ 43
ឧបសម្ព័ន្ធទី ២៖ កម្រងសំណួរ ........ 46

ឧបសម្ព័ន្ធទី ៣៖ Reliability......54

ឧបសម្ព័ន្ធទី ៤៖ គណៈកម្មការការពារនិក្ខេបបទ......54

# តារាង


តារាង 3.3. 1 ការជ្រើសរើសសំណាកស្រុក ........................................................................ 14

តារាង 3.3. 2 ការជ្រើសរើសសំណាកសសាលារៀន ............................................................... 14

តារាង 4.1. 2 លទ្ធផលគិតជាភាគរយលើទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀន៖ ឥរិយាបថក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន ................................................................. 22

តារាង 4.1. 3 លទ្ធផលគិតជាភាគរយលើទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀន៖ សារៈសំខាន់នៃការវាយតម្លៃ ................................................................................. 24

តារាង 4.2. 1 ភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនីមួយៗចំពោះការវាយតម្លៃបញ្ចប់ប្រចាំខែ ................................................................................................ 26

តារាង 4.2. 2 ភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនីមួយៗចំពោះការវាយតម្លៃបញ្ចប់មេរៀន ឬជំពូក ................................................................................................ 28

តារាង 4.2. 3 ភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនីមួយៗចំពោះការវាយតម្លៃជាប្រចាំ ....... 30

តារាង 4.3. 1 លទ្ធផលជ្រើសរើសរបស់គ្រូអំពីការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន៖ វិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន ............................................ 33

# រូបភាព

រូបភាព 2.3. 1 ការវាយតម្លៃដែលត្រូវបញ្ចូលក្នុងក្របខណ្ឌវាយតម្លៃនៅក្នុងប្រទេសកម្ពុជា ............ 8
រូបភាព 2.4. 1 ក្របខណ្ឌរបស់ការសិក្សាស្រាវជ្រាវ ............ 9
រូបភាព 3.2.3. 1 ភេទរបស់អ្នកចូលរួម ............ 15
រូបភាព 3.2.3. 2 អាយុរបស់អ្នកចូលរួម ............ 16
រូបភាព 3.2.3. 3 មុខវិជ្ជាបង្រៀន ............ 16
រូបភាព 3.2.3. 4 ចំនួនមុខវិជ្ជាកំពុងបង្រៀន ............ 17
រូបភាព 3.2.3. 5 ចំនួនកម្រិតថ្នាក់កំពុងបង្រៀន ............ 17
រូបភាព 3.2.3. 6 បទពិសោធន៍បង្រៀន ............ 18
រូបភាព 3.2.3. 7 សញ្ញាបត្រទទួលបានខ្ពស់បំផុត ............ 18
រូបភាព 3.2.3. 8 កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុត ............ 19

# មូលន័យសង្ខេប

ការវាយតម្លៃការសិក្សាត្រូវបានគេឱ្យតម្លៃខ្លាំង និងចាត់ទុកជាចំណុចអទិភាពមួយ ជាពិសេសការវាយតម្លៃកម្រិតថ្នាក់រៀនដែលអាចជួយបង្កើនគុណភាពនៃការសិក្សារៀនសូត្ររបស់សិស្ស។ ប៉ុន្តែ ការយល់ដឹងពីការអនុវត្តការវាយតម្លៃ និងការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ ហាក់នៅមិនទាន់មានភាពទូលំទូលាយនិងមានសង្គតិភាពនឹងគ្នានៅឡើយ។ ហើយ បើតាមលទ្ធផលនៃតេស្តរង្វាយតម្លៃថ្នាក់ជាតិ និងការវាយតម្លៃផ្សេងៗ បានបង្ហាញថាគ្រូបង្រៀន និងសិស្សហាក់ដូចជាមិនទាន់មានភាពច្បាស់លាស់ចំពោះការវាយតម្លៃនោះទេ ហើយក៏មិនទាន់បានអនុវត្តការវាយតម្លៃដោយប្រើប្រាស់យុទ្ធវិធីសំបូរបែបដែរ។

ការសិក្សានេះមានគោលបំណង ដើម្បីពិនិត្យមើលពីការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនៅកម្រិតថ្នាក់រៀន ការយល់ឃើញ និងយុទ្ធសាស្ត្រនៃការវាយតម្លៃរបស់លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀននៅវិទ្យាល័យនៅក្នុងខេត្តកំពង់ធំ ចំពោះការអនុវត្តការវាយតម្លៃទាំងនេះ។

វិធីសាស្ត្រដែលអ្នកសិក្សាស្រាវជ្រាវយកមកប្រើដើម្បីប្រមូលទិន្នន័យនោះ គឺវិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Method) ។ អ្នកស្រាវជ្រាវ បានប្រើកម្រងសំណួរទម្រង់បិទចំនួន ៤៨សំណួរដោយចែកជាបីបណ្តុំធំៗ៖ បណ្តុំទី១ ទស្សនៈរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន(សំណួរទី ១០.១ ដល់ ១០.១១) បណ្តុំទី២ យុទ្ធសាស្ត្រក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន (សំណួរទី ១១.១ ដល់ សំណួរ ១១.២៨) និងបណ្តុំទី៣ ការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន(សំណួរទី ១២.១ ដល់១២.៩)។ ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ ។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី WINDEM ដើម្បីបញ្ចូល និងគ្រប់គ្រងទិន្នន័យ និងប្រើកម្មវិធី SPSS សម្រាប់ស្វែងរកចំនួនប្រេកង់គិតជាភាគរយ និង Microsoft Excel សម្រាប់ធ្វើតារាង និងបកស្រាយព័ត៌មាន។ នៅក្នុងនេះផងដែរ អ្នកស្រាវជ្រាវបានជ្រើសរើសភាគសំណាកគ្រូចំនួនសរុប ២១០ នាក់ ស្រីចំនួន ៩៦ នាក់ មកពីវិទ្យាល័យចំនួន១០ ក្នុងស្រុកបារាយណ៍ ស្ទឹងសែន ស្ទោង និងស្រុកសន្ទុក ក្នុងខេត្តកំពង់ធំ។

លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា គ្រូបង្រៀនភាគច្រើនលើលលុបមានឥរិយាបថវិជ្ជមានចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន និងបានគិតថា ការវាយតម្លៃកម្រិតថ្នាក់រៀនពិតជាមានសារៈសំខាន់សម្រាប់ជំរុញគុណភាពបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព។ ប៉ុន្តែ ចំពោះការប្រើប្រាស់យុទ្ធវិធីក្នុងការវាយតម្លៃហាក់នៅមានកម្រិត ដោយគ្រូបង្រៀនធ្វើការវាយតម្លៃប្រចាំខែកម្រិតថ្នាក់រៀនមិនបានផ្តោតសំខាន់លើកម្មវិធីសិក្សាថ្នាក់ជាតិទេ។ មិនតែប៉ុណ្ណោះ ការប្រឡងប្រចាំខែមិនបានប្រើប្រាស់សំណួរដែលមានទម្រង់ចម្រុះនោះទេ ការវាយតម្លៃកម្រិតថ្នាក់រៀនមិនបានផ្តោតលើសមត្ថភាព (competency-based assessment) ឬលទ្ធផលសិក្សារបស់សិស្ស (performance-based assessment) ទេ ពួកគាត់ផ្តោតតែទៅលើចំណេះដឹងរបស់សិស្សតែប៉ុណ្ណោះ។ ទទឹមនឹងនេះ លោកគ្រូអ្នកគ្រូបានប្រើប្រាស់លទ្ធផលពីការវាយតម្លៃក្នុងគោលបំណងច្រើនប្រភេទ ប៉ុន្តែមិនទាន់បានប្រើប្រាស់លទ្ធផលនេះដើម្បីកំណត់រកពីគុណភាពសំណួរតេស្តនិងវិញ្ញាសាទេ និងមិនបានអនុវត្តតាមការណែនាំរបស់ក្រសួងអប់រំដែលបានសំណូមពរឱ្យលោកគ្រូអ្នកគ្រូធ្វើការវិភាគលទ្ធផលតាមសំណួរនីមួយៗ។

ជារួម បើទោះជាលោកគ្រូអ្នកគ្រូមានឥរិយាបថវិជ្ជមានចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន និងបានគិតថាការវាយតម្លៃកម្រិតថ្នាក់រៀនពិតជាមានសារៈសំខាន់សម្រាប់ជំរុញគុណភាពនៃការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព ប៉ុន្តែមានចំណុចប្រឈមជាច្រើនដែលត្រូវជំរុញបន្ថែមដូចជា ការប្រើយុទ្ធវិធីឱ្យកាន់តែចម្រុះ ការអនុវត្តបន្ថែមនៃការវាយតម្លៃផ្អែកលើសមត្ថភាពនិងលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងការប្រើប្រាស់លទ្ធផលពីការវាយតម្លៃឱ្យកាន់តែទូលំទូលាយ។

# ជំពូកទី១

# សេចក្តីផ្តើម

ជំពូកនេះ បញ្ជាក់លម្អិតពី ចំណុចរងតូចៗចំនួនប្រាំមួយដូចជា៖ ចំណុចរងទី១ បង្ហាញពីសារៈសំខាន់នៃការស្រាវជ្រាវ ចំណុចទី២ និយាយពីចំណោទបញ្ហានៃការស្រាវជ្រាវ ឯចំណុចទី៣ បរិយាយពីគោលបំណងនៃការស្រាវជ្រាវ។ ចំណុចទី៤ និយាយពីសំណួរស្រាវជ្រាវ ចំណែកចំណុចទី៥ និងទី៦ បង្ហាញជូនពី សារៈសំខាន់នៃការស្រាវជ្រាវ និង ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ។

## ១.១ សាវតារនៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធអប់រំ ៦+៣+៣ សម្រាប់ការអប់រំចំណេះទូទៅ ចាប់តាំងពីឆ្នាំ១៩៩៦មកទល់ពេលបច្ចុប្បន្ន។ ប្រព័ន្ធនេះសំដៅដល់សិស្សានុសិស្ស ត្រូវសិក្សានៅក្នុង ៦ឆ្នាំនៅកម្រិតបឋមសិក្សា(ពីថ្នាក់ទី១ដល់ទី៦) ៣ឆ្នាំនៅកម្រិតមធ្យមសិក្សាបឋមភូមិ(ពីថ្នាក់ទី៧ដល់ទី៩) និង៣ឆ្នាំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ពីថ្នាក់ទី១០ ដល់ទី១២)។ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ថា កម្រិតបឋមសិក្សាពីថ្នាក់ទី១ដល់ទី៦ ជាភូមិសិក្សាដែលសិស្សគ្រប់រូបចាំបាច់ត្រូវតែបញ្ចប់ (MoEYS, 2014)។ ចំណែកឯការអប់រំមូលដ្ឋានវិញត្រូវបានកំណត់ពីថ្នាក់ទី១ដល់ទី៩។ សិស្សទាំងអស់គួរតែបញ្ចប់យ៉ាងហោចណាស់ការអប់រំកម្រិតមូលដ្ឋាន មុននឹងពួកគេចេញទៅធ្វើការឬចាប់យកជំនាញបច្ចេកទេសផ្សេងៗ។

ចំណែកឯប្រព័ន្ធបណ្តុះបណ្តាលគ្រូវិញក៏មានការផ្លាស់ប្តូរច្រើនដំណាក់កាលផងដែរ តាំងពី ៦+១ បន្ទាប់មក ៩+១ ក្រោយមក ៩+២ និង១២+២ ជាដើម ។ មានន័យថា ដើម្បីក្លាយជាគ្រូបង្រៀន បេក្ខជន បេក្ខនារី គ្រាន់តែបញ្ចប់ថ្នាក់ទី៦ ហើយទទួលបានការបណ្តុះបណ្តាល លើផ្នែកគរុកោសល្យពីរបៀបនៃការបង្រៀន គាត់អាចក្លាយជាគ្រូបង្រៀនបានហើយ។ រហូតបកដល់បច្ចុប្បន្ននេះ អ្នកដែលចង់ក្លាយខ្លួនជាគ្រូបង្រៀន ពួកគេត្រូវបញ្ចប់ការសិក្សាចំណេះទូទៅដោយប្រឡងជាប់ថ្នាក់ទី១២ ហើយបានចូលរួមវគ្គបណ្តុះបណ្តាលផ្នែកវិធីសាស្ត្របង្រៀន និងគរុកោសល្យចំនួនពីរឆ្នាំ នោះពួកគាត់អាចក្លាយជាគ្រូបង្រៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិបានហើយ។ ចំណែកគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិវិញ ពួកគេត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងទទួលបានការបណ្តុះបណ្តាលផ្នែកគរុកោសល្យចំនួនមួយឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំ ត្រូវបានក្លាយជាគ្រូបង្រៀនពេញសិទ្ធិ។

ប៉ុន្តែប្រព័ន្ធអប់រំទាំងមូលត្រូវបាននឹងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅ។ ចាប់តាំងពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន គ្រប់ផ្នែកទាំងអស់ត្រូវបានស្ថិតក្រោមការកែលម្អ និងអភិវឌ្ឍន៏។ តួយ៉ាងដូចជា ក្នុងឆ្នាំ២០១៤ ចំណុចអាទិភាពចំនួនប្រាំបី ត្រូវបានដាក់ចេញដើម្បីធ្វើការកែទម្រង់ដំបូងគេ ក្នុងនោះរួមមាន កំណែទម្រង់ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន កំណែទម្រង់ការប្រឡងថ្នាក់ជាតិ កំណែទម្រង់ប្រព័ន្ធ

វាយតម្លៃលទ្ធផលសិក្សាសិស្ស កំណែទម្រង់ឧត្តមសិក្សា។ ប៉ុន្តែចំណុចអាទិភាពទាំងនោះត្រូវបានបំបែកបន្ថែមរហូតដល់ទៅ១៥ចំណុច បន្ទាប់ពីក្រសួងអប់រំបានធ្វើការពិនិត្យឡើងវិញពីស្ថានភាពអប់រំនៅពាក់កណ្តាលអណត្តិ កាលពីឆ្នាំ២០១៥។ ចំណុចទាំងនោះមានរួមមាន៖ ១) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២) កាពង្រាយគ្រូបង្រៀន ៣) ការបណ្តុះបណ្តាលគ្រូ ៤) គុណវុឌ្ឍិគ្រូបង្រៀន ៥) ការងារអធិការកិច្ច ៦) ការវាយតម្លៃលទ្ធផលសិក្សា ៧) ការប្រឡង ៨) កម្មវិធីសិក្សា ៩) កសាង និងជួសជុលអគារសិក្សា ១០) គុណភាពអប់រំនៅមធ្យមសិក្សា ១១) ការងារកីឡា ១២) ការងារយុវជន ១៣) ការអប់រំបច្ចេកទេស ១៤) ការកសាងសាលាជំនាន់ថ្មី និង១៥) ការបណ្តុះបណ្តាលនាយកសាលា (MoEYS, 2016)។

ដូចដែលបានឃើញខាងលើ ក្រសួងអប់រំក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើប្រព័ន្ធអធិការកិច្ច និងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាពិសេសនៅក្នុងកម្រិតមធ្យមសិក្សាចំណេះទូទៅ។ ក្រសួងអប់រំបានជម្រុញឱ្យមានការអនុវត្តការវាយតម្លៃផ្សេងៗដែលមានលក្ខណៈចម្រុះ និងមានគ្រប់កម្រិតទាំងអស់។ ប៉ុន្តែក្រឡេកមើលពីអតីតកាលវិញយើងឃើញថា ពីមុននិងរហូតដល់ទស្សវត៍៩០ ប្រទេសកម្ពុជាក៏បានអនុវត្តការវាយតម្លៃផ្សេងៗជាច្រើនដែរ។ ក៏ប៉ុន្តែ ការវាយតម្លៃទាំងនេះហាក់បានផ្តោតសំខាន់តែទៅលើការវាយតម្លៃទ្រង់ទ្រាយតូច និងមិនមានលក្ខណៈចម្រុះឡើយ (MoEYS, 2017)។ ទើបតែ ក្នុងអំឡុងឆ្នាំ២០០៥ ក្រសួងអប់រំបានចាប់ផ្តើមបង្កើតឱ្យមានតេស្តវង្វាយតម្លៃទ្រង់ទ្រាយធំ និងដែលបានចាប់ផ្តើមអនុវត្តជាផ្លូវការនៅអំឡុងឆ្នាំ ២០០៧ ។

ក្រៅពីជម្រុញឱ្យមានការវាយតម្លៃច្រើនប្រភេទមក ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបង្កើតឱ្យមានជាក្របខណ្ឌការវាយតម្លៃមួយដែលក្របខណ្ឌនេះសំដៅធ្វើយ៉ាងឱ្យមានការឯកភាពគ្នាក្នុងការអនុវត្តការវាយតម្លៃទាំងអស់នោះ (MoEYS, 2018a)។ ជាងនេះទៅទៀត ក្របខណ្ឌក៏មានបំណងដើម្បីធ្វើសុខដុមភាព និង ជម្រុញការអនុវត្តនិងការប្រើប្រាស់លទ្ធផលដែលទទួលបានមកពីការវាយតម្លៃទាំងនោះឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព។ ជាងនេះទៅទៀត ក្របខណ្ឌក៏មានបំណងដើម្បីធ្វើសុខដុមភាព និងជម្រុញការអនុវត្ត និងការប្រើប្រាស់លទ្ធផលដែលទទួលបានមកពីការវាយតម្លៃទាំងនោះឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព។ មិនតែប៉ុណ្ណោះនៅក្នុងក្របខណ្ឌនៃការវាយតម្លៃនេះ បានកំណត់យ៉ាងច្បាស់ពីការវាយតម្លៃទៅតាមកម្រិតផ្សេងៗ ដូចជាការវាតម្លៃកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ការប្រឡងបញ្ចប់ភូមិសិក្សា ការវាយតម្លៃកម្រិតសាលារៀន និងការវាយតម្លៃកម្រិតថ្នាក់រៀន។

ជារួម ការអប់រំអភិវឌ្ឍធនធានមនុស្ស គឺស្ថិតក្នុងគោលនយោបាយដំបូងគេរបស់រាជរដ្ឋាភិបាល។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ន ការវាយតម្លៃត្រូវបានគេឱ្យតម្លៃយ៉ាងខ្លាំង។ នៅក្នុងសាកលលោក ការវាយតម្លៃត្រូវបានចាត់ទុកជាចំណុចអាទិភាព[1] ។ ក្នុងចំណោមការវាយតម្លៃគ្រប់កម្រិត ការវាយតម្លៃដែលអាចជួយបង្កើនគុណភាពនៃកសិក្សារៀនសូត្ររបស់សិស្ស គឺការវាយតម្លៃកម្រិតថ្នាក់រៀន។ ការវាយតម្លៃកម្រិតថ្នាក់រៀនជាទូទៅត្រូវបានចាត់ទៅក្នុង

[1] ដកស្រង់ចេញពីគេហទំព័រ: https://www.oecd.org/site/educeri21st/40600533.pdf

ប្រភេទការវាយតម្លៃតាមដំណាក់ដើម្បីអភិវឌ្ឍការសិក្សារបស់សិស្ស។ គ្រូបង្រៀនប្រើការវាយតម្លៃលទ្ធផលសិក្សាសិស្សកម្រិតសាលារៀនដើម្បីកែលម្អការសិក្សាឱ្យកាន់តែប្រសើរឡើង។

ប៉ុន្តែ ការយល់ដឹង ការអនុវត្តការវាយតម្លៃ និងការប្រើប្រាស់លទ្ធផលនៃការការវាយតម្លៃ ហាក់នៅមិនទាន់មានភាពទូលំទូលាយនិងមានសង្គតិភាពនឹងគ្នានៅឡើយ (Yuankun Yao, 2015)។ ហើយ បើតាមលទ្ធផលនៃតេស្តវង្វាយតម្លៃថ្នាក់ជាតិ និងការវាយតម្លៃផ្សេងៗ បានបង្ហាញថាគ្រូបង្រៀន និងសិស្សហាក់ដូចជាមិនទាន់មានភាពច្បាស់លាស់ចំពោះការវាយតម្លៃទេ ហើយក៏មិនទាន់បានអនុវត្តការវាយតម្លៃដោយប្រើប្រាស់យុទ្ធវិធីសំបូរបែបដែរ។ តួយ៉ាងដូចជា របាយការណ៍លទ្ធផលសិក្សារបស់សិស្ស ដែលបានមកពីតេស្តវង្វាយតម្លៃថ្នាក់ជាតិនៅក្នុងឆ្នាំ ២០១៧ និង២០១៨ បានបង្ហាញថា សិស្សហាក់មិនមានភាពសុាំជាមួយការធ្វើតេស្តដោយប្រើសំណួរពហុជ្រើសចំណែកឯគ្រូបង្រៀនវិញមិនសូវបានប្រើប្រាស់សំណួរតេស្តបែបពហុជ្រើសរើសផងដែរ (MoEYS,2017),(MoEYS, 2018b) ដែលនេះជាការបង្ហាញពីការធ្វើតេស្តតែទៅលើផ្នែកណាមួយ និងមិនទាន់បានប្រើវិធី ឬសកម្មភាពច្រើនបែបក្នុងការអនុវត្តការវាយតម្លៃផងដែរ។

ការវាយតម្លៃទាំងនេះក៏បានបង្ហាញដែរថា គ្រូបង្រៀនមួយចំនួនបានគិតថា ការការអនុវត្តការធ្វើតេស្តវង្វាយតម្លៃដោយប្រើប្រាស់សំណួរតេស្តជាពហុជ្រើសរើស គឺមិនបានធ្វើឱ្យសិស្សគិតបានច្រើនទេ។ ចំណុចទាំងអស់នេះហាក់បានបង្ហាញថា ការអនុវត្តការវាយតម្លៃផ្សេងៗនៅក្នុងប្រទេសកម្ពុជាហាក់ដូចជានៅមានកម្រិតច្រើនជាពិសេសបញ្ហានៅក្នុងកម្រិតថ្នាក់រៀន។ ហេតុនេះហើយ ទើបយើងខ្ញុំចង់ធ្វើការស្រាវជ្រាវអំពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃផ្សេងៗ ជាពិសេសការវាយតម្លៃកម្រិតថ្នាក់រៀន។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានេះមានគោលបំណងចុងក្រោយ គឺដើម្បីពិនិត្យមើលពីការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនៅកម្រិតថ្នាក់រៀន ការយល់ឃើញ និងយុទ្ធសាស្ត្រនៃការវាយតម្លៃរបស់លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀននៅវិទ្យាល័យនៅក្នុងខេត្តកំពង់ធំ ចំពោះការអនុវត្តការវាយតម្លៃទាំងនេះ។ ជាងនេះទៅទៀត ការសិក្សាអាចជួយផ្តល់ជាអនុសាសន៍ដល់អ្នកគោលនយោបាយ ដើម្បីជម្រុញការអនុវត្តការវាយតម្លៃនៅកម្រិតថ្នាក់រៀនក្នុងគោលបំណងបង្កើនលទ្ធផលសិក្សារបស់សិស្ស។ ដើម្បីសម្រេចបាននូវការសិក្សានេះ អ្នកស្រាវជ្រាវបានបំបែកជាវត្ថុបំណងជាក់លាក់ចំនួនដែលបម្រើឱ្យគោលបំណងធំខាងលើដូចខាងក្រោម៖

- ស្វែងយល់ពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃការសិក្សារបស់សិស្ស
- កំណត់រកយុទ្ធសាស្ត្រនៃការវាយតម្លៃការសិក្សារបស់សិស្សដែលកំពុងអនុវត្តកម្រិតថ្នាក់រៀន
- ពិនិត្យមើលពីរបៀបដែលលោកគ្រូអ្នកគ្រូបានប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃទាំងនោះ

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីមានភាពស៊ីជម្រៅក្នុងការស្វែងរក និងសម្រេចបានតាមគោលបំណង និងវត្ថុបំណងខាងលើ ការសិក្សាត្រូវឆ្លើយតបទៅនឹងសំណួរមួយចំនួនដូចខាងក្រោម៖

១).តើលោកគ្រូអ្នកគ្រូយល់ឃើញដូចម្តេចខ្លះចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន?

២). តើយុទ្ធសាស្ត្រអ្វីខ្លះដែលគ្រូបង្រៀនកំពុងប្រើប្រាស់សម្រាប់ការវាយតម្លៃនៅកម្រិតថ្នាក់រៀន?

៤). តើលោកគ្រូអ្នកគ្រូបានប្រើប្រាស់លទ្ធផលរង្វាយតម្លៃទាំងនោះដើម្បីអ្វីខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ជួយផ្តល់ផលប្រយោជន៍ជាច្រើនដល់ការអប់រំយើងជាពិសេសលើផ្នែកវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងអ្នកគោលនយោបាយ។ តាមរយៈលទ្ធផលដែលបានមកពីការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវ អាចនឹងផ្តល់ព័ត៌មានដល់ថ្នាក់ដឹកនាំក្រសួងដើម្បីបានដឹងពីស្ថានភាពពិតប្រាកដនៃការអនុវត្តការវាយតម្លៃជាពិសេសការវាយតម្លៃកម្រិតថ្នាក់រៀន។ ជាងនេះទៅទៀត អ្នកស្រាវជ្រាវអាចកំណត់បានថា តើក្របខណ្ឌនៃការវាយតម្លៃមានប្រសិទ្ធិភាពនៅថ្នាក់ក្រោមជាតិដែរឬទេ។ តាមរយៈលទ្ធផលនេះ ជាឱកាសមួយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡាត្រូវពិនិត្យលើយន្តការណ៍បន្ថែមទៀតដើម្បីជំរុញការវាយតម្លៃនៅថ្នាក់ក្រោមជាតិ។ ដូច្នេះ ការសិក្សានេះ មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការរួមចំណែកក្នុងកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្នុងការរួមចំណែកបង្កើននូវគុណភាពសិក្សារបស់សិស្សានុសិស្សដែលជាសរសរទ្រូងដ៏សំខាន់សម្រាប់អភិវឌ្ឍប្រទេសជាតិទៅថ្ងៃអនាគត។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះជាករណីសិក្សានៅក្នុងខេត្តកំពង់ធំដោយសារពេលវេលា និងថវិកាមានកំណត់។ ការសិក្សានេះមានវិសាលភាពគ្របដណ្តប់ និងធ្វើទៅលើលោកគ្រូអ្នកគ្រូទាំងអស់ដែលកំពុងបង្រៀននៅក្នុងសាលាមធ្យមសិក្សាទុតិយភូមិចំនួន១០ នៅក្នុងស្រុកចំនួន៨ នៅក្នុងខេត្តកំពង់ធំទាំងមូល។ ហើយការសិក្សានេះផ្តោតទៅលើតែតេស្តរង្វាយតម្លៃកម្រិតថ្នាក់រៀនប៉ុណ្ណោះ ខណៈដែលការវាយតម្លៃផ្សេងៗទៀត ដូចជាកម្រិតថ្នាក់ជាតិ និងអន្តរជាតិ (ឬហៅម្យ៉ាងទៀតថា ការវាយតម្លៃទ្រង់ទ្រាយធំ) ការប្រឡងថ្នាក់ជាតិ និងការវាយតម្លៃកម្រិតសាលារៀន មិនត្រូវបានបញ្ចូលក្នុងការសិក្សានេះឡើយ។

# ជំពូក២

# រំលឹកទ្រឹស្ដី

ផ្នែកនេះនឹងធ្វើការពណ៌នាពី ៤ ចំណុចរងបន្ថែម។ ចំណុចរងទី១ បរិយាយអំពីនិយមន័យពាក្យគន្លឹះ ហើយចំណុចរងទី២ និយាយអំពីការប្រើប្រាស់ការវាយតម្លៃ។ ចំណែក ចំណុចរងទី៣ នឹងបង្ហាញពីប្រភេទនៃការវាយតម្លៃ ខណៈដែលចំណុចរងចុងក្រោយបរិយាយ ពីយុទ្ធសាស្រ្តក្នុងការវាយតម្លៃ។ ចំណុចរងទាំងអស់នោះ ត្រូវបានរៀបរាប់ដូចខាងក្រោម។

## ២.១ និយមន័យពាក្យគន្លឹះ

ការសិក្សាស្រាវជ្រាវនេះមានពាក្យគន្លឹះមួយចំនួនដូចជា ការវាយតម្លៃ តេស្តវង្វាយតម្លៃ ការវាយតម្លៃកម្រិតថ្នាក់រៀន និងមធ្យមសិក្សាទុតិយភូមិ។ ពាក្យទាំងនេះត្រូវបានឱ្យនិយមន័យទៅតាមបរិបទដូចខាងក្រោម។

**ការវាយតម្លៃ** សំដៅដល់ដំណើរការប្រមូល សំយោគ វិភាគ និងបកប្រែទិន្នន័យដើម្បីធ្វើការសម្រេចចិត្តណាមួយ។ ជាងនេះទៅទៀត ការវាយតម្លៃសំដៅដល់ការវាយតម្លៃដោយប្រើតេស្ត ឬហៅថា តេស្តវង្វាយតម្លៃ និងការវាយតម្លៃដោយមិនប្រើតេស្ត ដែលកំពុងត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធអប់រំទាំងមូលនៅក្នុងប្រទេសកម្ពុជា។

**តេស្តវង្វាយតម្លៃ** សំដៅដល់ការធ្វើការវាយតម្លៃដោយប្រាស់តេស្ត ឬកម្រងសំណួរតេស្ត ដែលអាចជាសំណួរ ឬជាលំហាត់ផ្សេងៗ។ សំណួរតេស្តទាំងនោះ អាចជាសំណួរទម្រង់បើក ឬសំណួរទម្រង់បិទ។ តេស្តវង្វាយតម្លៃជាផ្នែកមួយនៃការវាយតម្លៃ។

**ការវាយតម្លៃកម្រិតថ្នាក់រៀន** គឺសំដៅដល់ការវាយតម្លៃទាំងឡាយណាដែលកើតមាននៅក្នុងថ្នាក់រៀន (MoEYS, 2018a) និងមានគោលបំណងសំខាន់ គឺដើម្បីធ្វើយ៉ាងណាឱ្យការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្សកាន់តែមានលក្ខណៈប្រសើរឡើងសំដៅលើកកម្ពស់គុណភាពអប់រំទាំងមូល។ ការវាយតម្លៃទាំងនេះ ធ្វើឡើងដោយប្រើតេស្ត ឬមិនប្រើតេស្ត (test and non-test)។

**មធ្យមសិក្សាទុតិយភូមិ** សំដៅដល់ភូមិសិក្សាពីថ្នាក់ទី១០ដល់ថ្នាក់ទី១២នៅចំណោះទូទៅ។

## ២.២ គោលនយោបាយពាក់ព័ន្ធនឹងការវាយតម្លៃ

ក្នុងឆ្នាំ២០០៦ ក្រសួងអប់រំបានចេញគំរូនៃការវាយតម្លៃសម្រាប់ការអប់រំកម្រិតមូលដ្ឋាន(ពីថ្នាក់ទី១ដល់ថ្នាក់ទី៩) មុខវិជ្ជាភាសាខ្មែរ (MoEYS, 2007b) គណិតវិទ្យា (MoEYS, 2007a) វិទ្យាសាស្រ្ត (MoEYS, 2007c)និងវិទ្យាសាស្រ្តសង្គម (MoEYS, 2007d)។ នៅក្នុងសេចក្តីណែនាំនោះ ក៏បានបញ្ជាក់ដែរថា តាមរយៈការអនុវត្តការវាយតម្លៃដែលត្រឹមត្រូវ អាចធ្វើឱ្យលោកគ្រូអ្នកគ្រូទទួលបានព័ត៌មានផ្សេងៗពាក់ព័ន្ធនឹង១) ភាពរីកចម្រើនកម្រិតស្ទាត់ជំនាញខាងចំណេះដឹង និងបំណិនរបស់សិស្ស ២) កម្រិតលទ្ធផលដែលពួកគេសម្រេចបានធៀបនឹងលទ្ធផល

សិក្សា ឬស្តង់ដាដែលបានកំណត់ ៣) វិធីសាស្ត្រក្នុងការបង្រៀន ក៏ដូចជាសមត្ថភាពរបស់ខ្លួន និង ៤) កង្វះខាតរបស់គ្រូ និងសិស្សហើយជួយគ្រូឱ្យបង្រៀនសិស្សកាន់តែប្រសើរ ។

> "[...] *ម្យ៉ាងទៀតលទ្ធផលនោះ អាចបញ្ជាក់ប្រាប់ទៅសិស្សវិញផងដែរអំពីកម្រិតយល់ដឹង ការរីកចម្រើននៃសមត្ថភាពរបស់ខ្លួន។ គំរូកិច្ចការវាយតម្លៃនេះ* [...] *ផ្តោតសំខាន់ទៅលើសិស្សពិសេស ស្តង់ដា និងលទ្ធផលដែលសិស្សសំរេចបានដូចជាចំណេះដឹង បំណិន និងតម្លៃជាដើម។* [...] *ការវាយតម្លៃនេះនឹងផ្តល់ជាគំនិត ឧទាហរណ៍ ដល់លោកគ្រូ អ្នកគ្រូក្នុងការវាយតំលៃលទ្ធផលនៃការសិក្សារបស់សិស្ស ដែលផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍការបង្រៀន និងរៀនឱ្យបានស៊ីជម្រៅ និងជាក់លាក់។* [...]"
> (MoEYS, 2007)

ជាមួយគ្នានេះដែរ នៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០១៤-២០១៨ ក៏បានសង្កត់ធ្ងន់លើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សផងដែរ (MoEYS, 2014)។ ជាឧទាហរណ៍ ក្រសួងអប់រំបានរំលេចចេញពីតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ហើយក៏បានសង្កត់ធ្ងន់លើការបណ្តុះបណ្តាលដល់ថ្នាក់ក្រោមជាតិ ដើម្បីឱ្យពួកគេអាចអនុវត្តបានត្រឹមត្រូវនិងមានប្រសិទ្ធិភាពលើការវាយតម្លៃលទ្ធផលសិក្សាសិស្សនៅកម្រិតសាលារៀន និងកម្រិតថ្នាក់រៀន ។ នៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ បានបញ្ជាក់ថា ត្រូវលើកកម្ពស់គុណភាពនៃការវាយតម្លៃគ្រប់ប្រភេទ ជាពិសេសនៅថ្នាក់ក្រោមជាតិ។

នៅកំឡុងឆ្នាំ ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យប្រើប្រាស់នូវក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ។ នៅក្នុងក្របខណ្ឌបានលើកឡើងពីការពង្រឹងការវាយតម្លៃផ្សេងៗ ដើម្បីធានាឱ្យបាននូវការអនុវត្តក្របខណ្ឌកម្មវិធីសិក្សា។ ក្រសួងអប់រំបានលើកឡើងពីប្រភេទនៃការវាយតម្លៃ ជាពិសេសការវាយតម្លៃនៅកម្រិតថ្នាក់រៀន។ ក្រសួងបានបញ្ជាក់ថា ការវាយតម្លៃកម្រិតសាលារៀន និងការវាយតម្លៃកម្រិតថ្នាក់រៀន ត្រូវធ្វើឡើងនៅក្នុងសាលានីមួយៗ ដើម្បីវាស់ស្ទង់ពីការអនុវត្តកម្មវិធីសិក្សានៅកម្រិតសាលារៀន (MoEYS, 2015)។ ក្រសួងបានបន្ថែមទៀតថា ការវាយតម្លៃនេះត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនដើម្បីបង្កើនគុណភាពអប់រំនៅក្នុងស្ថាប័នរបស់ពួកគេ (MoEYS, 2015 ទំព័រ 17)។

ជាងនេះទៅទៀត ក្នុងពេលថ្មីៗនេះ ក្រសួងអប់រំយុវជន និងកីឡាបានដាក់ចេញឱ្យប្រើប្រាស់នូវក្របខណ្ឌការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់ថ្នាក់មធ្យមសិក្សាទុតិយភូមិ។ ការដាក់ចេញនេះ គឺក្នុងគោលបំណងសំខាន់ដើម្បីជម្រុញឱ្យការអនុវត្តការវាយតម្លៃគ្រប់ប្រភេទ គ្រប់កម្រិតទាំងអស់បានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ (MoEYS, 2018a)។ ក្នុងនោះដែរ ការវាយតម្លៃកម្រិតថ្នាក់រៀន ត្រូវបានចាត់ទុកថាការវាយតម្លៃដែលមានសារៈសំខាន់ និងត្រូវតែអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ក្រសួងបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងក្របខណ្ឌថ្មីនេះថា គោលដៅចុងក្រោយបង្អស់នៃការវាយតម្លៃ គឺដើម្បីកែប្រែ និងអភិវឌ្ឍការបង្រៀន និងរៀននៅកម្រិតថ្នាក់រៀន និងសាលារៀន (MoEYS, 2018a)។

## ២.៣ ប្រភេទនៃការវាយតម្លៃ

នៅក្នុងការស្រាវជ្រាវជាច្រើន បានធ្វើការបែងចែកការវាយតម្លៃទៅតាមប្រភេទផ្សេងៗដោយផ្អែកលើគោលបំណងរបស់ការវាយតម្លៃ។ ការសិក្សាមួយចំនួន បានបែកចែកការវាយតម្លៃទាំងអស់ជាបីប្រភេទគឺ ការវាយតម្លៃការសិក្សា(Assessment of learning) ការវាយតម្លៃសម្រាប់អភិវឌ្ឍការសិក្សា (Assessment for learning ) និងការវាយតម្លៃដើម្បីរៀនសូត្ររបៀបពីការវាយតម្លៃ (Assessment as learning)។ លោក អាដេឌីវ៉ា (Alaba Adeyemi Adediwura, 2012) បានញែកពីភាពខុសគ្នារបស់ការវាយតម្លៃការសិក្សា និងការវាយតម្លៃសម្រាប់អភិវឌ្ឍន៍ការសិក្សារបស់សិស្ស។ លោកលើកឡើងថា ការវាយតម្លៃការសិក្សារបស់សិស្ស សំដៅដល់ការវាយតម្លៃដែលត្រូវធ្វើឡើងបន្ទាប់ពីអំឡុងនៃការរៀនណាមួយត្រូវបានបញ្ចប់ ឬនៅខាងចុងបញ្ចប់នៃមេរៀនណាមួយដើម្បីធ្វើការប្រៀបធៀប ឬ ជ្រើសរើស ឬដើម្បីជាគណនីយភាពអ្វីមួយ។ ចំណែកការវាយតម្លៃសម្រាប់អភិវឌ្ឍន៍ការសិក្សាវិញ សំដៅដល់ការវាយតម្លៃសកម្មភាព ឬការវាយតម្លៃផ្សេងៗដែលធ្វើឡើងក្នុងគោលបំណងទទួលបានព័ត៌មាន យោបល់ ចំណុចខ្លាំង ចំណុចខ្សោយ ឬហេតុនិងផលដើម្បីជួយបង្កើនគុណភាពនៃការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស (Alaba Adeyemi Adediwura, 2012)។ ភ្ជាប់ជាមួយគ្នានេះ ការវាយតម្លៃដើម្បីរៀនសូត្ររបៀបពីការវាយតម្លៃ គឺសំដៅលើការទទួលយក ឬអនុវត្តតាមពីរបៀបនៃការវាយតម្លៃណាមួយដែលធ្វើទៅទទួលបានផលល្អ ឬគួរតែត្រូវបានអនុវត្តតាមក្នុងបរិបទណាមួយជាក់លាក់។

ការស្រាវជ្រាវផ្សេងទៀតបានចែកការវាយតម្លៃតែជាពីរផ្នែកសំខាន់ប៉ុណ្ណោះគឺ ការវាយតម្លៃតាមដំណាក់សម្រាប់ការអភិវឌ្ឍការសិក្សារបស់សិស្ស (Formative Assessment) និងការវាយតម្លៃបញ្ចប់ (Summative Assessment)។ ការវាយតម្លៃតាមដំណាក់ដើម្បីអភិវឌ្ឍការសិក្សា គឺជាការវាយតម្លៃទាំងឡាយណាដែលមានគោលបំណងចុងក្រោយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងរៀន ចំណែកឯ ការវាយតម្លៃបញ្ចប់ ជាការវាយតម្លៃទាំងឡាយណាដែលមានគោលបំណងចុងក្រោយបង្អស់ គឺដើម្បីវាស់ស្ទង់អំពីលទ្ធផលសិក្សារបស់អ្នកសិក្សា (Sayed Ahmad Javid Mussawy, 2009)។ លើសពីនេះ លោក Adediwura បានបន្ថែមថា ការវាយតម្លៃសម្រាប់អភិវឌ្ឍការសិក្សា ជាការវាយតម្លៃតាមដំណាក់សម្រាប់ការអភិវឌ្ឍការសិក្សារបស់សិស្សហើយការវាយតម្លៃការសិក្សាជាការវាយតម្លៃបញ្ចប់ (Alaba Adeyemi Adediwura, 2012)។

បើតាមក្របខណ្ឌនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សរបស់ប្រទេសកម្ពុជា ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៨នេះ ការវាយតម្លៃ គឺមានច្រើន និងកំពុងត្រូវបានអនុវត្តនៅក្នុងការអប់រំនៅក្នុងប្រទេសកម្ពុជាយើង (MoEYS, 2018a)។ ប៉ុន្តែតាមរយៈក្របខណ្ឌនេះ ការវាតម្លៃទាំងនោះត្រូវបានធ្វើសុខដុមកម្មតាមរយៈការដាក់បញ្ចូលគ្នា ឬមិនត្រូវបានរាប់បញ្ចូលជាតេស្តផ្លូវការជាដើម។

**រូបភាព 2.3. 1 ការវាយតម្លៃដែលត្រូវបញ្ចូលក្នុងក្របខណ្ឌវាយតម្លៃនៅក្នុងប្រទេសកម្ពុជា**




*ប្រភព៖ ក្របខណ្ឌការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ (MoEYS, 2018b, ទំព័រ ១៦)*

យោងតាមក្របខណ្ឌការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ ការវាយតម្លៃទាំងអស់ត្រូវបានដាក់បញ្ចូលជាពីរបណ្តុំធំៗសំខាន់ គឺការវាយតម្លៃផ្ទៃក្រៅ និងការវាយតម្លៃផ្ទៃក្នុង។ ការវាយតម្លៃផ្ទៃក្រៅចែកជាពីរថ្នាក់ទៀត គឺការវាយតម្លៃទ្រង់ទ្រាយធំកម្រិតប្រព័ន្ធ និងការប្រឡងថ្នាក់ជាតិ។ ចំណែកការវាយតម្លៃផ្ទៃក្នុងរួមមាន ការវាយតម្លៃកម្រិតសាលារៀន និងការវាយតម្លៃកម្រិតថ្នាក់រៀន (រូបភាពទី៤.១)។

ការវាយតម្លៃទ្រង់ទ្រាយធំកម្រិតប្រព័ន្ធ ជាបណ្តុំនៃការវាយតម្លៃបញ្ចប់ដែលត្រូវបានដឹកនាំអនុវត្តដោយអ្នកខាងក្រៅសាលា (MoEYS, 2018a)ដែលរួមមាន៖ ការវាយតម្លៃសិស្សថ្នាក់អន្តរជាតិ (PISA-D) ការវាយតម្លៃសិស្សថ្នាក់តំបន់(SEA PLM) តេស្តវាយតម្លៃលទ្ធផលសិក្សាសិស្សថ្នាក់ជាតិ តេស្តវាយតម្លៃអំណានថ្នាក់ដំបូង និងតេស្តវាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង។ ឯការប្រឡងថ្នាក់ជាតិ ដែលមានការប្រឡងថ្នាក់ជាតិ ថ្នាក់ទី៩ និងការប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២ ក៏ត្រូវបានចាត់ចូលក្នុងប្រភេទការវាយតម្លៃបញ្ចប់ និងត្រូវបានដឹកនាំអនុវត្តដោយអ្នកពីខាងក្រៅសាលាដែរ។

ការវាយតម្លៃកម្រិតសាលារៀន ជាការវាយតម្លៃដែលកើតឡើងនៅក្នុងសាលារៀន និងត្រូវបានដឹកនាំធ្វើដោយសាលាផ្ទាល់ (MoEYS, 2018b)។ ការវាយតម្លៃនេះរួមមាន ***ការប្រឡងឆមាស*** ការវាយតម្លៃកម្រិតថ្នាក់មត្តេយ្យ/ត្រៀមខ្លួនចូលសាលា និងការប្រឡងឡើងថ្នាក់។ ចំណែកឯការវាយតម្លៃកម្រិតថ្នាក់រៀនវិញសំដៅដល់ការវាយតម្លៃត្រូវបានរៀបចំ និងធ្វើឡើងដោយគ្រូបង្រៀននៅក្នុងថ្នាក់ផ្ទាល់តែម្តង។ ការវាយតម្លៃនេះរាប់បញ្ចូលការប្រឡងប្រចាំខែ និងការវាយតម្លៃជាប្រចាំដើម្បីអភិវឌ្ឍន៍។

## ២.៤ ក្របខណ្ឌរបស់ការសិក្សានេះ

ដូចបង្ហាញជូនខាងលើ មានការវាយតម្លៃជាច្រើនបាននឹងកំពុងអនុវត្តនៅក្នុងប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជាយើង។ សម្រាប់ការវាយតម្លៃកម្រិតថ្នាក់រៀន បើតាមក្របខណ្ឌការវាយតម្លៃ មានការប្រឡងប្រចាំខែ និងការវាយតម្លៃជាប្រចាំសម្រាប់អភិវឌ្ឍន៍។ ប៉ុន្តែការប្រឡងឆមាសក៏ត្រូវបានចាត់ថាជាការវាយតម្លៃកម្រិតថ្នាក់រៀនដែរ។ ដូច្នេះ ការសិក្សានេះ នឹងផ្តោតសំខាន់លើការវាយតម្លៃទាំងបីនេះ។

***រូបភាព** 2.4. 1 **ក្របខណ្ឌរបស់ការសិក្សាស្រាវជ្រាវ***




* ចំពោះយុទ្ធសាស្ត្រដែលប្រើប្រាស់នៅក្នុងការវាយតម្លៃ អាចជាតេស្ត ឬមិនមែនជាតេស្ត។ ការប្រើតេស្តសំដៅលើការប្រើប្រាស់ជាសំណួរតេស្ត ឬបណ្តុំសំណួរនៅលើក្រដាស ឬឧបករណ៍អេឡិចត្រូនិចផ្សេងៗដើម្បីឱ្យសិស្សធ្វើ។ ដែលតេស្តទាំងនេះអាចជា តេស្តស្តង់ដា(គ្រប់គ្រូនិងថ្នាក់ទាំងអស់នៃមុខវិជ្ជាតែមួយប្រើប្រាស់តេស្តតែមួយ) តេស្តបញ្ចប់មេរៀននីមួយៗ តេស្តដែលលោកគ្រូអ្នកគ្រូបានបង្កើតដោយខ្លួនឯងចំណែកយុទ្ធវិធីដែលមិនប្រើប្រាស់តេស្តវិញ សំដៅដល់ការវាយតម្លៃដោយប្រើវិធីផ្សេងៗដូចជា ការប្រើប្រាស់ ទំនាក់ទំនងជាលក្ខណៈបុគ្គល (ការពិភាក្សាជាលក្ខណៈបុគ្គល ពិភាក្សាជាក្រុមតូចៗ(២ទៅ៥នាក់) ការសម្ភាសន៍) ការសង្កេត និងការយល់ឃើញ (ការចូលរួមផ្សេងៗរបស់សិស្ស និងអន្តរកម្មក្នុងថ្នាក់រៀន) លទ្ធផលសិក្សា (គម្រោងស្រាវជ្រាវផ្សេងៗ បង្កើតជា

រូបភាពផ្សេងៗ ការបង្ហាញ/បទបង្ហាញផ្សេងៗ ការធ្វើជាវិដេអូ ឬសំឡេងផ្សេងៗ សុន្ទរកថា ឬសេចក្តីថ្លែងការផ្សេងៗ ការពិសោធន៍ផ្សេងៗ ការសរសេររបាយការណ៍ផ្សេងៗ និងការជជែកវែកញែកដេញដោលគ្នាផ្សេងៗ)។[2]

ដូចនេះ នៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានផ្តោតសំខាន់ទៅលើការវាយតម្លៃកម្រិតថ្នាក់រៀនដែលរួមមាន **ការប្រឡងប្រចាំខែ និងការវាយតម្លៃជាប្រចាំដើម្បីអភិវឌ្ឍន៍**។ ការសិក្សានេះនឹងស្វែងរកមើលផងដែរអំពីយុទ្ធវិធីដែលលោកគ្រូអ្នកគ្រូបានប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃ និងជាពិសេសពិនិត្យមើលពីការប្រើប្រាស់លទ្ធផលដែលបានមកពីការវាយតម្លៃទាំងនោះ។

## ២.៥ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន

ការសិក្សាស្រាវជ្រាវជាច្រើនដែលបានធ្វើលើការវាយតម្លៃកម្រិតថ្នាក់រៀន ដែលបានបង្ហាញពីការយល់ឃើញលោកគ្រូអ្នកគ្រូបង្រៀននៅក្នុងថ្នាក់ផ្ទាល់ ព្រមទាំងការយល់ឃើញរបស់អ្នកស្រាវជ្រាវផងដែរ ទៅលើអត្ថន័យ និងទិដ្ឋភាពទូទៅរបស់ការវាយតម្លៃកម្រិតថ្នាក់រៀន។

បើតាមការសិក្សារបស់លោកយ៉ាងគុណ (Yuankun Yao, 2015) បានបង្ហាញពីការយល់ឃើញរបស់ក្រុមគ្រូបង្រៀនគណិតវិទ្យានៅក្នុងសាលាមួយទៅលើអត្ថន័យរបស់ការវាយតម្លៃកម្រិតថ្នាក់រៀន។ លោកគ្រូអ្នកគ្រូយល់ថា ការវាយតម្លៃជាអ្វីៗដែលគ្រូបានធ្វើដើម្បីពិនិត្យមើលពីស្ថានភាពការសិក្សារបស់សិស្ស ដោយប្រើសកម្មភាពឬយុទ្ធវិធីផ្សេងៗ (Yao, 2015)។ ខណៈដែលគាត់ខ្លួនឯង (Yuankun Yao, 2015) យល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានការទាំងការវាយតម្លៃបញ្ចប់ និងការវាយតម្លៃតាមដំណាក់ដើម្បីអភិវឌ្ឍការសិក្សារបស់សិស្ស។ ការយល់ឃើញនេះមានភាពស្រប់គ្នាជាមួយលទ្ធផលសិក្សារបស់(Muhammad Saeed, HafsaTahir, & Iqra Latif, 2018) ដែលបានធ្វើឡើងក្នុងពេលថ្មីៗនេះ (2019)។

ម្យ៉ាងវិញទៀត មានអ្នកស្រាវជ្រាវមួយចំនួនបានឱ្យនិយមន័យថា ការវាយតម្លៃជាផ្នែកដ៏សំខាន់នៅក្នុងប្រព័ន្ធអប់រំ(Muhammad Saeed et al., 2018) ដែលអាចឆ្លុះបញ្ចាំង និងផ្តល់នូវព័ត៌មានយ៉ាងទូលំទូលាយអំពីការអភិវឌ្ឍនៃការសិក្សារបស់លោកគ្រអ្នកគ្រូនិងសិស្ស ព្រមទាំងលទ្ធផលសិក្សាផ្សេងៗដោយធៀបទៅនឹងការកំណត់ទុករបស់ការអប់រំ (Tajularipin Sulaiman, Suzieleez Syrene Abdul Rahim, Muhammad Nazrul Hakim, & Rosmaria Omar, 2019)។ Saeed និងសហការីបានបន្ថែមទៀតថា ការវាយតម្លៃសំដៅដល់ការប្រើប្រាស់យុទ្ធវិធីផ្សេងៗដែលអាចជួយបង្កើនគុណភាពរបស់បង្រៀន និងធ្វើការវាយតម្លៃលទ្ធផលសិក្សាដែលបានមកពីការបង្រៀននោះ។ ជាងនេះទៅទៀតពួកគាត់លើកឡើងថា ការវាយតម្លៃជាដំណើរការបង្រៀន និងរៀនដ៏មានប្រសិទ្ធភាព (Saeed, Hafsa and Iqra, 2018)។

---

[2] ដកស្រង់ចេញពីគេហទំព័រៈ
https://www.edu.gov.mb.ca/k12/cur/languages/spanish/s1tos4_found/assessment.pdf

ជាមួយគ្នានេះដែរ Sulaiman និងសហការី (2019) បានលើកឡើងពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូទៅលើធាតុសំខាន់ដែលត្រូវគិតអំពីក្នុងពេលអភិវឌ្ឍន៍ការវាយតម្លៃ។ ក្នុងនោះរួមមាន កម្រិតនៃការគិត ឬកម្រិតពុទ្ធិទៅតាមលោកប្លូមនិងសហការី (Level of Bloom's Taxonomy) ចំណេះដឹងដែលមានស្រាប់ សំណួរដែលមានតម្រូវការការគិតកម្រិតខ្ពស់ កម្រិតសមត្ថភាពរបស់សិស្ស និងតារាង/គម្រោងលម្អិតតេស្ត។ វាជាការប្រសើរបំផុតប្រសិនបើអាចបង្កើតតេស្តវាយតម្លៃដែលអាចបង្កើនការគិតរបស់សិស្ស អាចឱ្យសិស្សប្រើចំណេះដឹងជ្រៅជ្រះ និងជៀសវាងការប្រើតេស្តដោយគ្រាន់តែឱ្យសិស្សរំលឹកពីព័ត៌មានដែលបានរៀនកន្លងមកនោះ(Tajularipin Sulaiman et al., 2019)។

ជារួម ការវាយតម្លៃនៅក្នុងថ្នាក់រៀន គឺជាការប្រើប្រាស់នូវគ្រប់មធ្យោបាយដើម្បីធ្វើការពិនិត្យ វាស់វែង និងវាយតម្លៃអំពីលទ្ធផលសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូនៅក្នុងថ្នាក់ ដើម្បីធ្វើការកែលម្អការបង្រៀននិងរៀនសំដៅធ្វើយ៉ាងណាឱ្យគុណភាពអប់រំកើនឡើងជាប្រចាំ។ ការវាយតម្លៃត្រូវការគិតល្អិតល្អន់ដល់ធាតុសំខាន់ៗ និងត្រូវប្រើយុទ្ធវិធីផ្សេងៗដែលអាចអនុវត្តទៅបានដោយអ្នកអប់រំដើម្បីធ្វើការវាស់វែងអំពីឥទ្ធិផលរបស់ការបង្រៀន និងរៀនរបស់សិស្សនៅក្នុងថ្នាក់រៀន (Jarrett, 2016)។

## ២.៦ យុទ្ធសាស្ត្រក្នុងការវាយតម្លៃ

ដូចគ្នានឹងការយល់ឃើញដែរ មានការសិក្សាជាច្រើនបានលើកឡើងពីការយុទ្ធវិធីផ្សេងៗដែលត្រូវបានប្រើនៅក្នុងដំណើរការវាយតម្លៃ។ បើតាម Yao (2015) បានរកឃើញថា លោកគ្រូអ្នកគ្រូបានប្រើប្រាស់យុទ្ធសាស្ត្រ / សកម្មភាពផ្សេងៗដើម្បីធ្វើការវាយតម្លៃនៅក្នុងថ្នាក់រៀនរបស់ពួកគាត់ ដែលសកម្មភាពទាំងនោះរួមមាន ការសួរសំណួរទៅកាន់សិស្សជាបុគ្គល ឬជាក្រុម ការដើរទៅជិតសិស្សឬក្រុមសិស្សដើម្បីពិនិត្យមើលពីការវិវត្តន៍របស់សិស្ស ឬ ការឱ្យសិស្សធ្វើការងារជាបុគ្គលជាដើម (p.54)។ ប៉ុន្តែ អ្វីដែលលោកគ្រូអ្នកគ្រូចូលចិត្តធ្វើជាងគេ គឺកិច្ចការគម្រោង ព្រោះថាវាអាចផ្តល់ឱកាសដល់សិស្សយកអ្វីដែលពួកគេបានរៀនទៅអនុវត្តន៍នៅក្នុងជីវិតប្រចាំថ្ងៃ។ គាត់បានបញ្ជាក់បន្ថែមទៀតថា ការសង្កេតទៅលើសកម្មភាពចូលរួមរបស់សិស្សរួមទាំងអន្តរកម្មផ្សេងៗ និងការធ្វើតេស្តឬការប្រឡងក៏ជាសកម្មភាព/យុទ្ធវិធីដែលសិស្សលោកគ្រូអ្នកគ្រូចូលចិត្តធ្វើនៅក្នុងថ្នាក់រៀនផងដែរ (Yao, 2015 p.54)។

ជាមួយគ្នានេះដែរ ក្រុមអ្នកស្រាវជ្រាវផ្សេងទៀតក៏បានបង្ហាញពីសកម្មភាព/យុទ្ធវិធីដែលត្រូវបានប្រើប្រាស់នៅក្នុងថ្នាក់រៀនផងដែរ។ ជាឧទាហរណ៍ ក្រុមអ្នកស្រាវជ្រាវដែលរួមមាន Saeed, Hafsa and Iqra (2018) ដែលបានធ្វើការស្រាវជ្រាវជាមួយគ្រូបង្រៀនចំនួន៥០០នាក់ អំពីទស្សនៈរបស់ពួកគាត់លើការប្រើប្រាស់យុទ្ធវិធីផ្សេងៗក្នុងការវាយតម្លៃ បានបង្ហាញថា គ្រូបង្រៀងមានទំនួលខុសត្រូវក្នុងការប្រើយុទ្ធវិធីផ្សេងៗក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ឬគុណភាពនៃការវាយតម្លៃខ្លួនឯងផ្ទាល់ផងដែរ។ កន្លងមកគ្រូបង្រៀនបានប្រើប្រាស់យុទ្ធសាស្ត្រ/សកម្មភាពផ្សេងៗដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដូចជា កិច្ចការគម្រោង កម្រងសមិទ្ធផលសិក្សារបស់សិស្ស (Portfolio) ស្វ័យវង្វាយតម្លៃ ការវាយតម្លៃគ្នាទៅវិញទៅមក (peer evaluation) និងកិច្ចការស្រាវជ្រាវប្រចាំសប្តាហ៍ (assignments) ជាដើម (p.127)។ គ្រូបង្រៀនប្រុសបានប្រើប្រាស់យុទ្ធវិធីតាមបែបការវាយតម្លៃតាម

ដំណាក់ដើម្បីអភិវឌ្ឍ ខណៈគ្រូស្រីបានប្រើទាំងពីរ យុទ្ធវិធីដែលបម្រើឱ្យការវាយតម្លៃបញ្ចប់ និងការវាយតម្លៃតាមដំណាក់ដើម្បីអភិវឌ្ឍ (Muhammad Saeed et al., 2018)។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ការរៀបចំការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងសំណួរស្រាវជ្រាវទាំងបីខាងលើ អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្របែបបរិមាណវិស័យ ដោយប្រើសំណួរទម្រង់បើក(សំណួរដែលឱ្យអ្នកចូលរួមសរសេរចម្លើយបង្ហាញពីគំនិតខ្លួនឯង) និងសំណួរទម្រង់បិទ (សំណួរដែលមានចម្លើយឱ្យអ្នកចូលរួមជ្រើសរើសស្រាប់) ដើម្បីប្រមូលព័ត៌មានបានត្រឹមត្រូវតាមស្តង់ដាពីលោកគ្រូ អ្នកគ្រូមួយចំនួននៅតាមវិទ្យាល័យចំនួន១០ ក្នុងខេត្តកំពង់ធំ។

## ៣.២ ប្រជាករ (Population) និងសំណាកស្រាវជ្រាវ (Sample)

នៅក្នុងផ្នែកនេះ មានបង្ហាញពីប្រជាករ (Population) និងសំណាកស្រាវជ្រាវ(Sample) ដើម្បីធ្វើការស្រាវជ្រាវ។

### ៣.២.១ ប្រជាករ(Population)

យោងតាមស្ថិតិរបស់ក្រសួងអប់រំឆ្នាំ២០១៨-២០១៩ (MoEYS, 2019) ខេត្តកំពង់ធំមានមានស្រុកសរុបចំនួន ៨ ដែលមានអនុវិទ្យាល័យចំនួន ៦៧ និងវិទ្យាល័យចំនួន ២៤ ដែលមានបុគ្គលិកសរុបចំនួន ២ ០០៨នាក់ ស្រី ៨១៩។ ក្នុងការស្រាវជ្រាវនេះ កំណត់យកផ្នែកមធ្យមសិក្សាទុតិយភូមិ ដូចនេះអ្នកស្រាវជ្រាវធ្វើការជ្រើសទៅលើ១០ សាលាចេញពីស្រុកចំនួន៤ ធ្វើជាប្រជាករធ្វើជាមូលដ្ឋានដើម្បីជ្រើសរើសសំណាក។

ដោយសារប្រជាករជាក្រុមដែលមានសំណាកខុសៗគ្នាក្នុងស្រុកទាំង៨ ក្នុងខេត្តកំពង់ធំ អ្នកស្រាវជ្រាវបានជ្រើសរើសសំណាកសាកលជាពីរដំណាក់កាល (LOUIS COHEN, LAWRENCE MANION, & KEITH MORRISON, 2007)។ ដំណាក់កាលទី១ ជាដំណាក់កាលជ្រើសរើសស្រុកដោយកំណត់យក ៥០% នៃចំនួនស្រុកទាំងអស់ក្នុងខេត្តកំពង់ធំ និងដំណាក់កាលទី២ ជាដំណាក់កាលជ្រើសរើសសំណាកសាលារៀនដោយកំណត់ ៥០% នៃចំនួនសាលាក្នុងស្រុកនីមួយៗ។ ក្នុងការជ្រើសរើសសំណាកស្រុក និងសាលារៀន អ្នកស្រាវជ្រាវបានប្រើកម្មវិធី Excel ដើម្បីរៀបចំស្រុក និងសាលាក្នុងស្រុកទៅតាមលេខព្រាវ(Random) ដោយប្រើរូបមន្ត =RAND() ហើយរាប់តាមលំដាប់ព្រាវពីធំទៅតូចឱ្យគ្រប់ ៥០% តាមការកំណត់។ ដោយឡែកក្នុងក្រុងស្ទឹងសែន អ្នកស្រាវជ្រាវបានបញ្ចូលវិទ្យាល័យកំពង់ធំដើម្បីឱ្យបង្កើនចំនួនសំណាកស្រាវជ្រាវ និងធ្វើឱ្យទិន្នន័យកាន់តែមានភាពជឿជាក់ ខណៈដែលវិទ្យាល័យនេះមិនមានក្នុងលំដាប់ព្រាវ។

**តារាង** 3.3. 1 **ការជ្រើសរើសសំណាកស្រុក**

| ស្រុក/ក្រុង | | ឈ្មោះស្រុកដែលបានជ្រើសរើស | |
|---|---|---|---|
| ឈ្មោះស្រុក/ក្រុង | លំដាប់RAND() | ឈ្មោះស្រុក/ក្រុង | លំដាប់RAND() |
| បារាយណ៍ | 0.9234459 | បារាយណ៍ | 0.9234459 |
| កំពង់ស្វាយ | 0.0558413 | | |
| ស្ទឹងសែន | 0.5249861 | ស្ទឹងសែន | 0.5249861 |
| ប្រាសាទបល្ល័ង្គ | 0.053732 | | |
| ប្រាសាទសំបូរ | 0.3455291 | | |
| សណ្តាន់ | 0.350062 | | |
| សន្ទុក | 0.4162937 | សន្ទុក | 0.4162937 |
| ស្ទោង | 0.4532197 | ស្ទោង | 0.4532197 |

**តារាង** 3.3. 2 **ការជ្រើសរើសសំណាកសាលារៀន**

| ឈ្មោះស្រុក/ក្រុង | ចំនួនសាលាសរុប | ចំនួនសាលាដែលរើសបាន |
|---|---|---|
| បារាយណ៍ | ៦ | ៣ |
| ស្ទឹងសែន | ៣ | ៣ |
| ស្ទោង | ៤ | ២ |
| សន្ទុក | ៣ | ២ |
| សរុប | ១៦ | ១០ |

### ៣.២.២ សំណាកស្រាវជ្រាវ (Sample)

ក្នុងសំណាកសាលារៀនទាំង១០នេះ មានគ្រូបង្រៀនផ្នែកទុតិយភូមិសរុបទាំងអស់ចំនួន ៣០៨នាក់ សម្រាប់រើសមកធ្វើជាសំណាកស្រាវជ្រាវតាមរបៀបកំណត់សំណាកស្រាវជ្រាវរបស់ Krejcie & Morgan(1970)។ តាមវិធីនេះ អ្នកស្រាវជ្រាវកំណត់យកចំនួនគ្រូទាំងអស់តាមសាលានីមួយៗ(clustered Selection) ធ្វើជាប្រជាករ

(Population) ហើយកំណត់យកសំណាកស្រាវជ្រាវស្មើនឹងប្រជាករ នោះដែលកម្រិតជឿជាក់៩៩% និងកម្រិតលម្អៀង ១%។

### ៣.២.៣ លក្ខណៈទូទៅរបស់អ្នកចូលរួម

ការសិក្សានេះធ្វើការវាយតម្លៃទៅលើលោកគ្រូអ្នកគ្រូដែលកំពុងបង្រៀននៅសាលារៀនចំនួន១០ ក្នុងស្រុកចំនួន៤ ក្នុងខេត្តកំពង់ធំ។ ជាលទ្ធផល ទិន្នន័យអ្នកចូលរួមដែលទទួលបានសរុបមានចំនួន ២១០នាក់។ លក្ខណៈទូទៅរបស់អ្នកចូលរួមត្រូវបានពណ៌មានដូចខាងក្រោម។

- ភេទ

**រូបភាព** 3.2.3. 1 **ភេទរបស់អ្នកចូលរួម**




រូបភាព ៣.២.៣.១ បង្ហាញពីភាគរយអ្នកចូលរួមតាមភេទ។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានអ្នកចូលរួមដែលជាលោកគ្រូចំនួន ៥៤.៣% និងអ្នកគ្រូចំនួន ៤៥.៧%។

- អាយុរបស់អ្នកចូលរួម

រូបភាព ៤.៤ បង្ហាញពីភាគរយអ្នកចូលរួមតាមអាយុ។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានអ្នកចូលរួមដែលមានអាយុនៅចន្លោះពី២០ទៅ២៥ឆ្នាំចំនួន ០.៥% អាយុចន្លោះពី ២៦ដល់៣០ឆ្នាំមានចំនួន ១៦.៩% និងអាយុច្រើនជាង ៣០ឆ្នាំងមានដល់ទៅ៨២.៦%។

**រូបភាព** 3.2.3. 2 **អាយុរបស់អ្នកចូលរួម**




- មុខវិជ្ជាបង្រៀន

**រូបភាព** 3.2.3. 3 **មុខវិជ្ជាបង្រៀន**




រូបភាព ៤.៥ បង្ហាញពីភាគរយអ្នកចូលរួមតាមមុខវិជ្ជាដែលគាត់បាននឹងកំពុងបង្រៀន។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានអ្នកចូលរួមជាគ្រូភាសាខ្មែរ ១៥.៨% គ្រូគណិតវិទ្យាចំនួន១៤.៤% គ្រូវិទ្យាសាស្ត្រពិតចំនួន ៤៥% គ្រូវិទ្យាសាស្ត្រសង្គមចំនួន ១៧.៧% គ្រូភាសាអង់គ្លេសចំនួន ៧.២% និងគ្រូបង្រៀនមុខផ្សេងទៀតមាន ចំនួន ១.៩%។

- ចំនួនមុខវិជ្ជាដែលគ្រូម្នាក់បានបង្រៀនក្នុងឆ្នាំសិក្សាកន្លងមក

**រូបភាព** 3.2.3. 4 **ចំនួនមុខវិជ្ជាកំពុងបង្រៀន**




រូបភាព ៤.៦ បង្ហាញពីភាគរយអ្នកចូលរួមតាមចំនួនមុខវិជ្ជាដែលខ្លួនបាននឹងកំពុងបង្រៀន។ ក្នុងចំណោមអ្នកចូលរួមទាំងអស់ មានអ្នកចូលរួមចំនួន ៨៤.៥% កំពុងបង្រៀន១មុខវិជ្ជា លោកគ្រូអ្នកគ្រូចំនួន១៣.១%កំពុងបង្រៀន២មុខវិជ្ជា លោកគ្រូអ្នកគ្រូចំនួន០.៩%កំពុងបង្រៀន៣មុខវិជ្ជា និងលោកគ្រូអ្នកគ្រូចំនួន១.៤%កំពុងបង្រៀនច្រើនជាង៣មុខវិជ្ជា ។

- កម្រិតថ្នាក់កំពុងបង្រៀន

**រូបភាព** 3.2.3. 5 **ចំនួនកម្រិតថ្នាក់កំពុងបង្រៀន**




រូបភាព ៤.៧ បង្ហាញពីភាគរយអ្នកចូលរួមតាមចំនួនកម្រិតថ្នាក់ដែលខ្លួនបាននឹងកំពុងបង្រៀន។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានអ្នកចូលរួមចំនួន ២៨.២% កំពុងបង្រៀន១កម្រិតថ្នាក់ លោកគ្រូអ្នកគ្រូចំនួន

៥៤.៩%កំពុងបង្រៀន២កម្រិតថ្នាក់ លោកគ្រូអ្នកគ្រូចំនួន១៤.៦%កំពុងបង្រៀន៣កម្រិតថ្នាក់ និងលោកគ្រូអ្នកគ្រូចំនួន២.៤%កំពុងបង្រៀនច្រើនជាង៣កម្រិតថ្នាក់។

- បទពិសោធន៍បង្រៀន

**រូបភាព** 3.2.3. 6 **បទពិសោធន៍បង្រៀន**




រូបភាព ៤.៨ បង្ហាញពីភាគរយអ្នកចូលរួមតាមបទពិសោធន៍ដែលពួកគាត់មាន។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានអ្នកចូលរួមចំនួន ១១.៧% មានបទពិសោធន៍បង្រៀនពី១ដល់៥ឆ្នាំ លោកគ្រូអ្នកគ្រូចំនួន ២៦.៨% មានបទពិសោធន៍បង្រៀនពី៦ដល់១០ឆ្នាំ និងលោកគ្រូអ្នកគ្រូចំនួន ៦១.៥% មានបទពិសោធន៍បង្រៀនច្រើនជាង ១០ឆ្នាំ។

- សញ្ញាខ្ពស់បំផុតរបស់គ្រូបង្រៀន

**រូបភាព** 3.2.3. 7 **សញ្ញាបត្រទទួលបានខ្ពស់បំផុត**



រូបភាព ៤.៩ បង្ហាញពីភាគរយអ្នកចូលរួមតាមកម្រិតសញ្ញាបត្រខ្ពស់បំផុតរបស់ខ្លួនដែលមាន។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានអ្នកចូលរួមចំនួន ៩.៩% មានសញ្ញាបត្រខ្ពស់បំផុតទាបជាងបរិញ្ញាបត្រ លោកគ្រូអ្នកគ្រូចំនួន៦៩.៧% មានសញ្ញាបត្រខ្ពស់បំផុតត្រឹមបរិញ្ញាបត្រ លោកគ្រូអ្នកគ្រូចំនួន២០.២% មានសញ្ញាបត្រខ្ពស់បំផុតត្រឹមអនុបណ្ឌិត និងលោកគ្រូអ្នកគ្រូចំនួន០.៥% មានសញ្ញាបត្រខ្ពស់បំផុតត្រឹមបណ្ឌិត។

- កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុត

**រូបភាព 3.2.3. 8 កម្រិតបណ្ដុះបណ្ដាលវិជ្ជាជីវៈខ្ពស់បំផុត**




រូបភាព ៤.១០ បង្ហាញពីភាគរយអ្នកចូលរួមតាមកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុតដែលពួកគាត់មាន។ ក្នុងចំណោម អ្នកចូលរួមទាំងអស់ មានលោកគ្រូអ្នកគ្រូចំនួន ២.៨% បានទទួលកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុតត្រឹមគ្រូកម្រិតបឋមសិក្សា( ដែលរាប់តាំងពី ៩+១ ឬ៩+២ ឬ១២+២ ឬក្រៅពីនេះ) លោកគ្រូអ្នកគ្រូចំនួន ២០.៧% បានទទួលកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុតត្រឹមគ្រូកម្រិតមូលដ្ឋាន (ដែលរាប់តាំងពី ៩+១ ឬ៩+២ ឬ១២+២ ឬក្រៅពីនេះ) និងលោកគ្រូអ្នកគ្រូចំនួន ៧៦.៦% បានទទួលកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុតត្រឹមគ្រូកម្រិតឧត្តម (បរិញ្ញាបត្រ +១)។

## ៣.៤ ឧបករណ៍ស្រាវជ្រាវ

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ដោយប្រើកម្រងសំណួរសម្រាប់សួរគ្រូបង្រៀនដែលបង្រៀននៅវិទ្យាល័យកម្រិតទុតិយភូមិ(ទី១០ ដល់ទី១២)។ សំណួរចំនួន១១ (លេខ ១០.១ ដល់ ១០.១១) ជាឧបករណ៍វាស់បរិមាណវិស័យទៅលើទស្សនៈរបស់លោកគ្រូ អ្នកគ្រូចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន។ សំណួរចំនួន ២៨(លេខ១១.១ ដល់ ១១.២៨) ជាសំណួរបែបបរិមាណវិស័យវាស់ទៅលើយុទ្ធសាស្ត្រនៃការវាយតម្លៃកម្រិតថ្នាក់រៀន និងសំណួរពីលេខ ១២.១ ដល់ ១២.៩ វាស់វែងទៅលើការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដែលជាសំណួរបែបបរិមាណវិស័យ ។ ទន្ទឹមនឹងគ្នានេះដែរកម្រិតនៃភាពអាចជឿជាក់បាន (Reliability) យកក្នុងកម្រិត (០.៩២)។ ***(មើលឧបសម្ព័ន្ធទី ៣)***

### ៣.៤.១ កម្រងសំណួរស្ដីពីការវាយតម្លៃកម្រិតថ្នាក់រៀន

| ការវាយតម្លៃកម្រិតថ្នាក់រៀន | លេខសំណួរ |
|---|---|
| ទស្សនៈរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន | ១០.១, ១០.២ ១០.៣,១០.៤,១០.៥,១០.៦, ១០.៧,១០.៨, ១០.៩,១០.១០,១០.១១ |
| យុទ្ធសាស្រ្តការវាយតម្លៃកម្រិតថ្នាក់រៀន | ១១.១, ១១.២, ១១.៣,១១.៤,១១.៥,១១.៦, ១១.៧,១១.៨,១១.៩,១១.១០,១១.១១,១១.១២, ១១.១៣,១១.១៤,១១.១៥,១១.១៦,១១.១៧,១១.១៨,១១.១៩,១១.២០,១១.២១, ១១.២១, ១១.២១,១១.២៣,១១.២៤,១១.២៥,១១.២៦, ១១.២៧, និង១១.២៨ |
| ការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន | ១២.១, ១២.២, ១២.៣, ១២.៤, ១២.៥, ១២.៦, ១២.៧, ១២.៨, និង១២.៩ |

### ៣.៤.២ ប្រសិទ្ធភាពនៃឧបករណ៍ស្រាវជ្រាវ

ដើម្បីឱ្យកម្រងសំណួរមានភាពច្បាស់លាស់ និងទទួលបានលទ្ធផលមានភាពជឿជាក់បានអ្នកស្រាវជ្រាវបានយកឧបករណ៍នេះពិនិត្យយ៉ាងល្អិតល្អន់ និងសាកល្បងក្រុមគ្រូបង្រៀនចំនួន ២០រូបក្នុងស្រុកស្នួល ខេត្តក្រចេះដើម្បីបំពេញ។ បន្ទប់មកយកមកកែសម្រួលជាថ្មី សុំការឯកភាពពីគ្រូដឹកនាំ និងចាប់ផ្ដើមប្រមូលទិន្នន័យ ***(មើលឧបសម្ព័ន្ធទី ២)***។

## ៣.៥ ដំណើរការប្រមូលទិន្នន័យ

ពេលទទួលបានលិខិតជូនដំណឹងលេខ៖១៨៨៥.អយក.វជអ របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃព្រហស្បតិ៍ ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៨មេសា ឆ្នាំ២០១៩ និងលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ លេខ៖១១៩ វជអ.ផក ចុះថ្ងៃសុក្រ ១៤ កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្ដីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ៦ នៃវិទ្យាស្ថានជាតិអប់រំឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅតាមរាជធានី ខេត្តនានា និងដើម្បីសុំចំណារឯកភាពពីថ្នាក់ដឹកនាំមន្ទីរ ***(មើលឧបសម្ព័ន្ធ១)***។ បន្ទាប់ពីបានចំណារឯកភាពពីថ្នាក់ដឹកនាំមន្ទីរ អ្នកស្រាវជ្រាវបានថតចម្លង១០ច្បាប់ជូនសាលា និង៤ច្បាប់ទៀតជូនដំណឹងដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ហើយបញ្ជូនឯកសារទាំងអស់នោះទៅការិយាល័យអប់រំ យុវជន និងកីឡា និងសាលាមុនពេល និងនៅពេលចុះប្រមូលទិន្នន័យ។ ពេលដល់សាលានីមួយៗ អ្នកស្រាវជ្រាវ

បង្ហាញលិខិតជូនដំណឹង លិខិតឧទ្ទេសនាមបេសកកម្មចុះប្រមូលទិន្នន័យជូននាយកសាលា និងស្នើរឱ្យគាត់កោះប្រជុំលោកគ្រូអ្នកគ្រូដើម្បីធ្វើការណែនាំពីរបៀបបំពេញកម្រងសំណួរឱ្យបានត្រឹមត្រូវ និងភាពច្បាស់លាស់ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈរបស់អ្នកស្រាវជ្រាវ។ អ្នកឆ្លើយសំណួរបានចំណាយពេលចន្លោះពី ២០នាទី ទៅ៣០នាទីក្នុងការបំពេញកម្រងសំណួរនៅសាលារៀន និងមានលោកគ្រូអ្នកគ្រូខ្លះយកទៅបំពេញកម្រងសំណួរនៅផ្ទះដើម្បីកុំឱ្យប៉ះពាល់ម៉ោងបង្រៀនរបស់គាត់។ ដំណើរការប្រមូលទិន្នន័យចំណាយពេលប្រហែល៣សប្តាហ៏តាមការគ្រោងទុកតាមផែនការ និងដើម្បីឱ្យការស្រាវជ្រាវមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា។ អ្នកស្រាវជ្រាវ បានទំនាក់ទំនងទៅនាយកសាលាជាប្រចាំដើម្បីបំពេញបញ្ចប់ និងប្រមូលកម្រងសំណួរនោះមកវិញ។ ក្រោយពេលបំពេញកម្រងសំណួររួច លោកគ្រូ អ្នកគ្រូបានប្រគល់ជូននាយកសាលាដើម្បីរក្សាទុក និងផ្ញើរជូន ឬអ្នកស្រាវចុះទៅប្រមូលវិញដោយផ្ទាល់ខ្លួនឯង។

## ៣.៦ ការគ្រប់គ្រង និងវិភាគទិន្នន័យ

ការសិក្សានេះ បានប្រើកម្មវិធីមួយចំនួនដើម្បីគ្រប់គ្រង និងវិភាគទិន្នន័យ។ ដំបូងអ្នកស្រាវជ្រាវបើកកម្មវិធី WinDEM ដើម្បីបញ្ចូល ត្រួតពិនិត្យកំហុស និងការគ្រប់គ្រប់គ្រងទិន្នន័យផ្សេងៗ(កែកំហុស និងសម្អាត)។ បន្ទាប់ពីបញ្ចូលរួចរាល់ហើយ អ្នកស្រាវជ្រាវបម្លែងទិន្នន័យនោះពី WinDEM ទៅ SPSS ដើម្បីវិភាគ។ ក្នុងការវិភាគ អ្នកស្រាវជ្រាវបានប្រើស្ថិតិតាមបែបព័ណ៌នា។ ជាចុងក្រោយដើម្បីវិភាគចេញតារាង និងរូបភាពផ្សេងៗ អ្នកស្រាវជ្រាវបានប្រើកម្មវិធី Excel។ ជារួមក្នុងការគ្រប់គ្រង និងវិភាគទិន្នន័យ អ្នកស្រាវជ្រាវ បានប្រើកម្មវិធី WinDEM, SPSS និង Excel។

# ជំពូក៤

# លទ្ធផលការស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវរៀបរាប់ និងពន្យល់ពីលទ្ធផលការសិក្សាដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានលើកឡើងនៅជំពូកទី១។ ជំពូកនេះ អ្នកស្រាវជ្រាវបែងចែកលទ្ធផលជាបីបណ្តុំ។ លទ្ធផលទាំងនេះត្រូវបានបង្ហាញជូនដូចខាងក្រោមៈ

## ៤.១. លទ្ធផលសិក្សាស្រាវជ្រាវបណ្តុំទី១ៈ ទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀន

បណ្តុំនេះ អ្នកស្រាវជ្រាវចង់រកឱ្យពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូតាមសាលារៀន ដោយបានប្រើប្រាស់ប្រយោគចំនួន១១ ដើម្បីធ្វើការឆ្លុះបញ្ចាំងពីទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀន។ ក្នុងចំណោមប្រយោគទាំង១១ ត្រូវបានចែកជាពីរបណ្តុំរងទៀតគឺ ឥរិយាបថក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន(៤ប្រយោគ) និងសារៈសំខាន់នៃការវាយតម្លៃ(៧ប្រយោគ) (តារាង៤.១)។

- *ឥរិយាបថក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន*

**តារាង** 4.1. 1 **លទ្ធផលគិតជាភាគរយលើទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀនៈ ឥរិយាបថក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន**

| **ប្រយោគ** | | កម្រិតយល់ស្រប(%)* | | | | | |
|---|---|---|---|---|---|---|---|
| | | មិនយល់ស្រប | | | ច្រើនបំផុត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **ឥរិយាបថក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន** | | | | | | | |
| 10.1 | ខ្ញុំចូលចិត្តធ្វើការវាយតម្លៃកម្រិតថ្នាក់រៀន ព្រោះវាអាចជួយឱ្យខ្ញុំរកឃើញនូវសិស្សខ្លាំង មធ្យម និងខ្សោយ។ | 0.5 | 1.9 | 3.3 | 29.1 | 39,0 | 25.8 |
| 10.2 | ខ្ញុំចូលចិត្តធ្វើការវាយតម្លៃកម្រិតថ្នាក់រៀន ព្រោះវាយជួយកែលម្អការបង្រៀនរបស់ខ្ញុំ។ | 0 | .5 | 2.8 | 19.7 | 46.9 | 29.6 |
| 10.3 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនជាដំណើរការគួរឱ្យធុញទ្រាន់ និងធ្វើឱ្យខាតពេលក្នុងការបង្រៀន និងរៀន។ | 48.8 | 28.6 | 6.6 | 3.8 | 10.8 | .9 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 10.4 | ខ្ញុំយល់ថា មានការវាយតម្លៃជាច្រើនកំពុងអនុវត្តនៅក្នុងសាលារបស់ខ្ញុំ ដែលគួរតែកាត់បន្ថយខ្លះ។ | 38.5 | 25.4 | 14.6 | 10.4 | 7.0 | 2.8 |

** [0 =មិនយល់ស្របសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

លទ្ធផលការស្រាវជ្រាវតារាង ៤.១.១ ខាងលើបង្ហាញឱ្យឃើញថា ប្រយោគចំនួន៤ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីឥរិយាបថរបស់លោកគ្រូអ្នកគ្រូបទៅលើការវាយតម្លៃកម្រិតថ្នាក់រៀន។ បង្ហាញពីចំនួនប្រេកង់គិតជាភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនៃការយល់ស្រប(កម្រិតពី០ដល់៥ ដែល 0 មានន័យថា មិនយល់ស្របសោះ និង ៥ មានន័យថាយល់ស្របទាំងស្រុង)។ លទ្ធផលត្រូវបានបង្ហាញថា ចំពោះប្រយោគ "***ខ្ញុំចូលចិត្តធ្វើការវាយតម្លៃកម្រិតថ្នាក់រៀន ព្រោះវាអាចជួយឱ្យខ្ញុំរកឃើញនូវសិស្សខ្លាំង មធ្យម និងខ្សោយ។***" មានលោកគ្រូអ្នកគ្រូភាគច្រើន (ប្រមាណជា ៩៣.១% ដែលបានជ្រើសរើសយកកម្រិត ៣ ៤និង៥) បានយល់ទៅលើប្រយោគនេះ។ មានប្រមាណជា ៦.៩% ប៉ុណ្ណោះ ដែលមិនយល់ស្រចំពោះប្រយោគនេះ។ **នេះបញ្ជាក់ថា លោកគ្រូអ្នកគ្រូភាគច្រើនមានទស្សនៈវិជ្ជមានចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន។**

ចំពោះឃ្លា "***ខ្ញុំចូលចិត្តធ្វើការវាយតម្លៃកម្រិតថ្នាក់រៀន ព្រោះវាយជួយកែលម្អការបង្រៀនរបស់ខ្ញុំ។***" លទ្ធផលបង្ហាញថា មានគ្រូបង្រៀនភាគច្រើនប្រមាណជាជិត ៩៦.៧% បានជ្រើសរើសពីកម្រិតយល់ស្របពីលេខ៣ដល់លេខ៥។ នោះមានន័យថាលោកគ្រូអ្នកគ្រូភាគច្រើនបានឥរិយាបថវិជ្ជមានចំពោះការវាយតម្លៃ។ តែទោះជាយ៉ាងណាក៏ដោយក៏មានគ្រូមួយចំនួន(ប្រមាណជា ៣.៣%) មិនយល់នឹងឃ្លានេះដែរ។

រីឯប្រយោគ ដែលថា "***ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនជាដំណើរការគួរឱ្យធុញទ្រាន់ និងធ្វើឱ្យខាតពេលក្នុងការបង្រៀន និងរៀន។***" និង "***ខ្ញុំយល់ថា មានការវាយតម្លៃជាច្រើនកំពុងអនុវត្តនៅក្នុងសាលារបស់ខ្ញុំ ដែលគួរតែកាត់បន្ថយខ្លះ។***" លទ្ធផលបង្ហាញថា លោកគ្រូអ្នកគ្រូប្រមាណជា ៤៨.៨% និង ៣៨.៥% (រៀងគ្នា) បានជ្រើសរើសយកកម្រិតមិនយល់ស្របសោះ និងប្រមាណជា ៣៥.២% និង ៤០% បានជ្រើសរើសយក កម្រិត១ និង ២(រៀងគ្នា)។ ប៉ុន្តែ ចំណុចគួរចាប់អារម្មនោះគឺ មានគ្រូបង្រៀនប្រមាណជា ១៥%បានគិតយល់ស្រប(ចាប់ពីមធ្យមដល់ទាំងស្រុង)ទៅនឹងប្រយោគ "ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនជាដំណើរការគួរឱ្យធុញទ្រាន់ និងធ្វើឱ្យខាតពេលក្នុងការបង្រៀន និងរៀន។" និងប្រមាណជាជិត ២០% បានយល់ស្របទៅ(ចាប់ពីមធ្យមដល់ទាំងស្រុង)នឹងប្រយោគ "ខ្ញុំយល់ថា មានការវាយតម្លៃជាច្រើនកំពុងអនុវត្តនៅក្នុងសាលារបស់ខ្ញុំ ដែលគួរតែកាត់បន្ថយខ្លះ។" ។

- ***សារៈសំខាន់នៃការវាយតម្លៃ***

ប្រយោគចំនួន៧ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីការយល់ឃើញលោកគ្រូអ្នកគ្រូបង្រៀនទៅលើសារៈសំខាន់របស់ការវាយតម្លៃកម្រិតថ្នាក់រៀន។ តារាង៤.១ បង្ហាញពីចំនួនប្រេកង់គិតជាភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនៃការយល់ស្រប(កម្រិតពី០ដល់៥ ដែល 0 មានន័យថា មិនយល់ស្របសោះ និង ៥ មានន័យថាយល់ស្របទាំងស្រុង)

*តារាង 4.1. 2 លទ្ធផលគិតជាភាគរយលើទស្សនៈរបស់លោកគ្រូអ្នកគ្រូទៅលើការវាយតម្លៃកម្រិតថ្នាក់រៀនៈ សារៈសំខាន់នៃការវាយតម្លៃ*

| **ប្រយោគ** | | កម្រិតយល់ស្រប(%) | | | | | |
|---|---|---|---|---|---|---|---|
| | | មិនយល់ស្រប | | | ច្រើនបំផុត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **សារៈសំខាន់នៃការវាយតម្លៃ** | | | | | | | |
| 10.5 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានសារៈប្រយោជន៍ជួយដល់ការសិក្សារបស់សិស្ស។ | 0.5 | 1.4 | 2.3 | 17.8 | 38.0 | 38.5 |
| 10.6 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀន អាចជួយឱ្យខ្ញុំប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយពីតម្រូវការរបស់សិស្ស។ | 0.0 | 0.9 | 4.2 | 12.2 | 48.4 | 32.9 |
| 10.7 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនអាចឱ្យខ្ញុំដឹងពីការវិវឌ្ឍការសិក្សារបស់សិស្សពីមួយថ្ងៃទៅមួយថ្ងៃ។ | 0.9 | 0.9 | 19.7 | 19.8 | 42.3 | 34.7 |
| 10.8 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីលើកទឹកចិត្តសិស្ស មិនមែនជាការដាក់ពិន័យនោះទេ។ | 1.4 | 3.3 | 4.7 | 15.5 | 41.8 | 39.1 |
| 10.9 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានសារៈសំខាន់ណាស់ដែលអាចឱ្យគ្រូជួយសិស្សទាន់ពេលវេលា។ | 0.5 | 1.4 | 3.3 | 16.4 | 40.4 | 36.6 |
| 10.10 | ខ្ញុំយល់ថា ការវាយតម្លៃគ្មានសារៈប្រយោជន៍សម្រាប់ការបង្រៀនរបស់ខ្ញុំទេ។ | 73.7 | 11.3 | 4.7 | 5.2 | 2.8 | 0.9 |
| 10.11 | ខ្ញុំយល់ថា ការវាយតម្លៃធ្វើឱ្យសិស្សបាក់ទិកចិត្ត និងបោះបង់ការសិក្សា។ | 57.3 | 18.3 | 8.0 | 9.4 | 4.2 | 1.4 |

* *[0 =មិនយល់ស្របសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

មានគ្រូប្រមាណជាជិត ៩៥%បានយល់ស្របនឹងប្រយោគ ***«ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានសារៈប្រយោជន៍ជួយដល់ការសិក្សារបស់សិស្ស។»*** និងមានប្រមាណជា ៥% មិនយល់ស្របនឹងប្រយោគនេះ។ ចំពោះប្រយោគ ***«ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀន អាចជួយឱ្យខ្ញុំប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយពីតម្រូវការរបស់សិស្ស។»*** លទ្ធផលវិភាគបង្ហាញថា មានគ្រូបង្រៀនចំនួនប្រមាណជា ៩៤% បានយល់ស្របនិងប្រមាណជាជិត៦% មិនយល់ស្របនឹងប្រយោគនេះ។

ជាមួយគ្នានេះដែរ មានគ្រូប្រមាណជា ២%មិនយល់ស្របនឹងប្រយោគ *«ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនអាចឱ្យខ្ញុំដឹងពីការវិវឌ្ឍការសិក្សារបស់សិស្សពីមួយថ្ងៃទៅមួយថ្ងៃ។»* ខណៈដែលគ្រូបង្រៀនប្រមាណជា៩៨% មានបានបង្ហាញពីការយល់ស្របនឹងប្រយោគនេះ។ ចំពោះប្រយោគ *«ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីលើកទឹកចិត្តសិស្ស មិនមែនជាការដាក់ពិន័យនោះទេ។»* និង *«ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានសារៈសំខាន់ណាស់ដែលអាចឱ្យគ្រូជួយសិស្សទាន់ពេលវេលា។»* មានគ្រូប្រមាណជា ៩០% និង ៩៥% បានបង្ហាញពីអារម្មណ៍យល់ស្របទៅនឹងប្រយោគទាំងពីរ (រៀងគ្នា) ខណៈដែលមានគ្រូបង្រៀនប្រមាណជា ១០% និង ៥% បង្ហាញថា ពួកគាត់ហាក់មិនយល់ស្របនឹងប្រយោគទាំងពីរនេះ(រៀងគ្នា)។

ដូចគ្នាទៅនឹងប្រយោគខាងលើ ចំពោះប្រយោគ *«ខ្ញុំយល់ថា ការវាយតម្លៃគ្មានសារៈប្រយោជន៍សម្រាប់ការបង្រៀនរបស់ខ្ញុំទេ។»* និង *«ខ្ញុំយល់ថា ការវាយតម្លៃធ្វើឱ្យសិស្សបាក់ទឹកចិត្ត និងបោះបង់ការសិក្សា។»* មានអ្នកចូលរួមប្រមាណជា ៩១% និង ៨៨% បានបង្ហាញទស្សនៈមិនយល់ស្របនឹងប្រយោគទាំងពីរនេះ (រៀងគ្នា) មានតែប្រមាណជា ៩% និង ១២% (រៀងគ្នា) ប៉ុណ្ណោះដែលមានទស្សនៈស្របនឹងប្រយោគទាំងពីរនេះ។

ជារួមលទ្ធផលបណ្តុំទី១ អាចសរុបបានថាលោកគ្រូអ្នកគ្រូដែលបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ធំពេញចិត្តចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន ដោយពួកគាត់គិតថាដំណើរការវាយតម្លៃនេះពិតជាមានសារៈសំខាន់ដើម្បីការបង្រៀន និងរៀនឱ្យមានគុណភាព។

## ៤.២. បណ្តុំទី២៖ យុទ្ធសាស្ត្រនៃការអនុវត្តការវាយតម្លៃកម្រិតថ្នាក់រៀន

អ្នកស្រាវជ្រាវ បានប្រើប្រាស់ប្រយោគចំនួន២៨ ដើម្បីបង្ហាញពីយុទ្ធសាស្ត្រដែលលោកគ្រូអ្នកគ្រូបានធ្វើនៅពេលអនុវត្តការវាយតម្លៃកម្រិតថ្នាក់រៀន។ ក្នុងចំណោមប្រយោគទាំង២៨ ត្រូវបានចែកជាបីបណ្តុំរងទៀតគឺ ការវាយតម្លៃបញ្ចប់ប្រចាំខែ (ប្រឡងប្រចាំខែ) (មាន១១ប្រយោគ) ការវាយតម្លៃបញ្ចប់មេរៀន ឬជំពូក (មាន៤ប្រយោគ) និង ការវាយតម្លៃជាប្រចាំ (គ្រប់ម៉ោងបង្រៀន) (១៤ប្រយោគ) (តារាង៤.៣, ៤.៤, និង៤.៥ ខាងក្រោម)។

- **ការវាយតម្លៃបញ្ចប់ប្រចាំខែ (ប្រឡងប្រចាំខែ)**

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានផ្តល់ប្រយោគចំនួន១០ដល់អ្នកចូលរួមជ្រើសរើស ដើម្បីបង្ហាញពីការអនុវត្តការវាយតម្លៃបញ្ចប់ប្រចាំខែ។ លទ្ធផលបានបង្ហាញក្នុងតារាង ៤.២.១ ខាងក្រោម។

**តារាង** 4.2. 1 **ភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនីមួយៗចំពោះការវាយតម្លៃបញ្ចប់ប្រចាំខែ**

| **ប្រយោគ** | | កម្រិតអនុវត្ត | | | | | |
|---|---|---|---|---|---|---|---|
| | | មិនបានអនុវត្ត | | | បានអនុវត្ត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **ការវាយតម្លៃបញ្ចប់ប្រចាំខែ** (**ប្រឡងប្រចាំខែ**) | | | | | | | |
| 11.1 | ខ្ញុំ និងគ្រូបង្រៀនមុខវិជ្ជាដូចគ្នាដ៏ទៃផ្សេងទៀត ធ្វើការវាយតម្លៃប្រចាំខែ ដោយប្រើប្រាស់វិញ្ញាសាតែមួយដូចគ្នា។ | 49.8 | 12.0 | 10.0 | 17.2 | 6.7 | 4.3 |
| 11.2 | ខ្ញុំ និងគ្រូបង្រៀនមុខវិជ្ជាដូចគ្នាដ៏ទៃទៀត ធ្វើការវាយតម្លៃប្រចាំខែដោយប្រើប្រាស់វិញ្ញាសាផ្សេងគ្នា។ | 2.9 | 6.7 | 4.3 | 8.6 | 36.8 | 40.7 |
| 11.3 | នៅពេលរៀបចំវិញ្ញាសាប្រឡងប្រចាំខែ ខ្ញុំប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោល និងសៀវភៅកម្មវិធីសិក្សាលម្អិត ដែលរៀបរៀងដោយក្រសួងអប់រំ យុវជន និងកីឡា។ | 71.8 | 7.2 | 5.7 | 6.2 | 6.2 | 2.9 |
| 13.4 | មុនពេលចាប់ផ្ដើមតាក់តែងសំណួរតេស្ត ខ្ញុំតែងតែរៀបចំតារាងគម្រោងលម្អិតវិញ្ញាសាប្រឡងប្រចាំខែ។ | 66.2 | 10.8 | 8.0 | 7.5 | 4.7 | 2.8 |
| 11.5 | នៅពេលតាក់តែងសំណួរតេស្ត ខ្ញុំបានគិតដល់កម្រិតពុទ្ធិ តាមទ្រឹស្ដីបទប៊្លូម (Bloom's Taxonomy) នៃសំណួរ ដូចជាកម្រិត ចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។ | 8.9 | 8.5 | 9.9 | 17.4 | 30.5 | 24.9 |
| 11.6 | ដើម្បីកំណត់ចំនួនសំណួរដែលត្រូវដាក់ក្នុងមួយវិញ្ញាសារ ខ្ញុំត្រូវគិតចេញពីរយៈពេលសរុបសម្រាប់ធ្វើមួយវិញ្ញាសា។ ដោយខ្ញុំ បាន់ស្មានរយៈពេលសិស្សធ្វើសំណួរនីមួយៗ រួចបូកបញ្ចូលគ្នាស្មើនឹងរយៈពេលសរុប។ | 59.8 | 14.4 | 13.4 | 5.7 | 4.8 | 1.9 |
| 11.7 | ក្នុងមួយវិញ្ញាសា ខ្ញុំត្រូវតែធ្វើយ៉ាងឱ្យមានចំនួនសំណួរកម្រិតងាយតិច(20%) កម្រិតមធ្យមច្រើន (60%) និងកម្រិតលំបាកតិច (20%)។ | 3.8 | 2.4 | 6.7 | 8.6 | 43.5 | 34.9 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11.8 | ក្នុងមួយវិញ្ញាសា ខ្ញុំប្រើប្រាស់ទម្រង់សំណួរសរសេរ (សិស្សសរសេរចម្លើយដោយខ្លួនពួកគេផ្ទាល់) ភាគច្រើនបំផុត។ | 6.7 | 5.3 | 8.6 | 20.6 | 35.4 | 23.4 |
| 11.9 | ខ្ញុំមិនប្រើប្រាស់ទម្រង់ពហុជ្រើសរើសដោយសារខ្ញុំមិនចេះពីរបៀបបង្កើតវា។ | 50.2 | 13.4 | 12.4 | 9.6 | 8.1 | 6.2 |
| 11.10 | ខ្ញុំមិនប្រើប្រាស់ទម្រង់ពហុជ្រើសរើសដោយសារទម្រង់សំណួរនេះមិនមានប្រើនៅក្នុងវិញ្ញាសារប្រឡងមធ្យមសិក្សាទុតិយភូមិ។ | 22.5 | 12.0 | 5.3 | 17.2 | 19.6 | 23.4 |

* *[0 =មិនបានអនុវត្តសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

លទ្ធផលបានបង្ហាញថា មានគ្រូបង្រៀនចំនួនប្រមាណជាជិត ៧១.៨% បានរាយការណ៍ថា ពួកគាត់មិនបានអនុវត្តដោយជ្រើសរើសកម្រិត ០ ,១ និង២ ចំពោះប្រយោគ ***"ខ្ញុំ និងគ្រូបង្រៀនមុខវិជ្ជាដូចគ្នាដ៏ទៃផ្សេងទៀត ធ្វើការវាយតម្លៃប្រចាំខែ ដោយប្រើប្រាស់វិញ្ញាសាតែមួយដូចគ្នា។"*** ។ តែ ក៏មានគ្រូបង្រៀនមួយចំនួនជិត ៣០% បានធ្វើការវាយតម្លៃដោយប្រើវិញ្ញាសារួមគ្នាដែរ។ លទ្ធផលនេះ ហាក់ដូចជាឆ្លុះគ្នាទៅនឹងប្រយោគបន្ទាប់ដែលនិយាយថា ***"ខ្ញុំ និងគ្រូបង្រៀនមុខវិជ្ជាដូចគ្នាដ៏ទៃទៀត ធ្វើការវាយតម្លៃប្រចាំខែដោយប្រើប្រាស់វិញ្ញាសាផ្សេងគ្នា។"*** ដែលមានចំនួនគ្រូភាគច្រើននិយាយថា បានធ្វើច្រើនដល់ទៅកម្រិតទី៥។

ចំពោះឯកសារយោងសម្រាប់យកមកធ្វើសំណួរតេស្ត មានគ្រូប្រមាណជា ៧០% បានជ្រើសរើស ***"មិនដែលបានប្រើសោះ"*** ដែលឆ្លើយតបទៅនឹងប្រយោគដែលលើកឡើងថា ***"នៅពេលរៀបចំវិញ្ញាសាប្រឡងប្រចាំខែ ខ្ញុំប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោល និងសៀវភៅកម្មវិធីសិក្សាលម្អិត ដែលរៀបរៀងដោយក្រសួងអប់រំ យុវជន និងកីឡា។"*** ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានគ្រូប្រមាណជា ១៥% ដែលបានរាយការណ៍ថា បានប្រើប្រាស់ឯកសារទាំងនោះក្នុងពេលធ្វើសំណួរតេស្តដែរ។ ជាមួយគ្នានេះដែរ ក៏មានគ្រូបង្រៀនប្រហែលជា ៦៦% បានលើកឡើងថា ពួកគាត់មិនដែលធ្លាប់សោះ ក្នុងការដែលរៀបចំតារាងគម្រោងលម្អិតវិញ្ញាសាប្រឡងប្រចាំខែ មុនពេលពេលបង្កើតសំណួរតេស្តនិងវិញ្ញាសា។ ផ្ទុយទៅវិញ ក៏មានប្រមាណជាជិត ៣% នៃអ្នកចូលរួមដែលបានរាយការណ៍ថា បានរៀបចំគម្រោងលម្អិតតេស្តមុនចាប់ផ្តើមអភិវឌ្ឍសំណួរតេស្ត។

ឆ្លើយតបនឹងប្រយោគដែលបានផ្តល់ជូនថា ***"នៅពេលគាត់តែងសំណួរតេស្ត ខ្ញុំបានគិតដល់កម្រិតពុទ្ធិ តាមទ្រឹស្តីបទប៊្លូម (Bloom's Taxonomy) នៃសំណួរ ដូចជាកម្រិត ចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។"*** មានអ្នកចូលរួមភាគច្រើន(ប្រមាណជាជិត ៧៣%) បានជ្រើសរើសយកកម្រិតអនុវត្តលេខ ៣, ៤ និង៥ ដែលជាសញ្ញាណបញ្ជាក់ថា ពួកគាត់បានគិតដល់កម្រិតពុទ្ធិទាំងអស់នេះ កំឡុងពេលបង្កើតសំណួរតេស្ត។ ប៉ុន្តែ មានលោកគ្រូអ្នកគ្រូប្រហែល ៦០% បានឆ្លើយថា ពួកគាត់ "មិនដែលអនុវត្តសោះ" សកម្មភាពដែលបានបញ្ជាក់ក្នុង

ប្រយោគ *«ដើម្បីកំណត់ចំនួនសំណួរដែលត្រូវដាក់ក្នុងមួយវិញ្ញាសារ ខ្ញុំត្រូវគិតចេញពីរយៈពេលសរុបសម្រាប់ធ្វើមួយវិញ្ញាសា ដោយខ្ញុំ ប៉ាន់ស្មានរយៈពេលសិស្សធ្វើសំណួរនីមួយៗ រួចបូកបញ្ចូលគ្នាស្មើនឹងរយៈពេលសរុប។»*។ តែជាការគួរឱ្យចាប់អារម្មណ៍ មានលោកគ្រូអ្នកគ្រូភាគច្រើន (ប្រហែល៧៥%) បានបង្ហាញថា ពួកគាត់បានកំណត់ពិន្ទុសម្រាប់សំណួរតេស្តនីមួយៗតាមក្បួនខ្នាតត្រឹមត្រូវដោយពួកគាត់បានជ្រើសរើសកម្រិត ៣, ៤និង៥ (ប្រយោគលេខ ១៣.៧ ខាងលើ)។

ចំពោះប្រយោគ *«ក្នុងមួយវិញ្ញាសា ខ្ញុំត្រូវតែធ្វើយ៉ាងឱ្យមានចំនួនសំណួរកម្រិតងាយតិច(20%) កម្រិតមធ្យមច្រើន (60%) និងកម្រិតលំបាកតិច (20%)។»* មានលោកគ្រូអ្នកគ្រូ ប្រហែល ៨៧% បានបង្ហាញថា ពួកគាត់បានអនុវត្ត។ រីឯ ប្រយោគ *«ក្នុងមួយវិញ្ញាសា ខ្ញុំប្រើប្រាស់ទម្រង់សំណួរសរសេរ (សិស្សសរសេរចម្លើយដោយខ្លួនពួកគេផ្ទាល់) ភាគច្រើនបំផុត។»* មានលោកគ្រូអ្នកគ្រូ ៧៩% បានបង្ហាញថា ពួកគាត់បានអនុវត្តដូច្នោះ។ នេះបញ្ជាក់ថា ជាធម្មតាក្នុងវិញ្ញាសាប្រឡងនីមួយៗមិនមានបញ្ចូលប្រភេទសំណួរ ឬទម្រង់សំណួរចម្រុះទេ លោកគ្រូអ្នកគ្រូបង្រៀនបានផ្តោតសំខាន់ទៅលើសំណួរបើក។ អ្នកស្រាវជ្រាវក៏សួរបញ្ជាក់ពីមូលហេតុដែលនាំឱ្យពួកគាត់ធ្វើបែបនេះ តាមរយៈប្រយោគ *«ខ្ញុំមិនប្រើប្រាស់ទម្រង់ពហុជ្រើសរើសដោយសារខ្ញុំមិនចេះពីរបៀបបង្កើតវា។»* តែមានលោកគ្រូ អ្នកគ្រូភាគច្រើនហាក់មិនឯកភាពទេ ដែលភាគច្រើនគិតថា មកពីសំណួរពហុជ្រើសរើសមិនមានក្នុងវិញ្ញាសាប្រឡងមធ្យមសិក្សាទុតិយភូមិ (ប្រយោគលេខ ១១.៩ និង១១.១០ ខាងលើ)។

- ការវាយតម្លៃបញ្ចប់មេរៀន ឬ ជំពូក

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានផ្តល់ប្រយោគចំនួន៤ប្រយោគដល់អ្នកចូលរួមជ្រើសរើស ដើម្បីបង្ហាញពីការអនុវត្តការវាយតម្លៃបញ្ចប់មេរៀន ឬ ជំពូក។ លទ្ធផលបានបង្ហាញក្នុងតារាង ៤.២.២ ខាងក្រោម។

**តារាង** 4.2. 2 **ភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនីមួយៗចំពោះការវាយតម្លៃបញ្ចប់មេរៀន ឬ ជំពូក**

| **ប្រយោគ** | | កម្រិតអនុវត្ត | | | | | |
|---|---|---|---|---|---|---|---|
| | | មិនបានអនុវត្ត | | | បានអនុវត្ត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **ការវាយតម្លៃបញ្ចប់មេរៀន ឬ ជំពូក** | | | | | | | |
| 11.11 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយមេរៀន ដោយប្រើប្រាស់សំណួរតេស្តផ្សេងៗ នៅក្នុងថ្នាក់រៀនដែលទាក់ទងនឹងមេរៀននោះ។ | 23.9 | 22.0 | 18.2 | 16.3 | 10.0 | 9.6 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11.12 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយមេរៀន ដោយដាក់កិច្ចការផ្ទះ ជាលំហាត់ ឬ គម្រោងផ្សេងៗ ដែលទាក់ទងនឹងមេរៀននោះ។ | 4.3 | 5.7 | 4.8 | 15.8 | 38.8 | 30.6 |
| 11.13 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយជំពូក ដោយប្រើប្រាស់សំណួរ តេស្តផ្សេងៗ នៅក្នុងថ្នាក់រៀន ដែលទាក់ទងនឹងជំពូកនោះ។ | 27.3 | 23.0 | 12.0 | 12.9 | 14.8 | 10.0 |
| 11.14 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយជំពូក ដោយដាក់កិច្ចការផ្ទះជាលំហាត់ ឬ គម្រោងផ្សេងៗ ដែលទាក់ទងនឹងមេរៀននោះ។ | 8.6 | 4.3 | 11.0 | 25.8 | 25.8 | 24.4 |

* *[0 =មិនបានអនុវត្តសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

តារាង៤.២.២ ខាងលើកក៏បង្ហាញពីលទ្ធផលអំពីការវាយតម្លៃបញ្ចប់មេរៀន ឬជំពូក។ មានលោកគ្រូអ្នកគ្រូប្រមាណជា ២៤%បានឆ្លើយថា ពួកគាត់មិនបានប្រើប្រាស់សំណួរតេស្តផ្សេងៗ នៅក្នុងថ្នាក់រៀនដែលទាក់ទងនឹងមេរៀនមួយ ដើម្បីធ្វើការវាយតម្លៃបញ្ចប់មេរៀននោះទេ (ប្រយោគ ១១.១១)។ ប៉ុន្តែ មានលោកគ្រូអ្នកគ្រូភាគច្រើន (ប្រហែល ៨៥%) បានបញ្ជាក់ថា បានអនុវត្តទៅលើប្រយោគ *"ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយមេរៀន ដោយដាក់កិច្ចការផ្ទះ ជាលំហាត់ ឬ គម្រោងផ្សេងៗ ដែលទាក់ទងនឹងមេរៀននោះ។"*។ ដូចគ្នាដែរ ចំពោះការវាយតម្លៃបញ្ចប់ជំពូក លោកគ្រូអ្នកគ្រូប្រមាណជា ២៧% មិនប្រើប្រាស់សំណួរតេស្តដើម្បីធ្វើការវាយតម្លៃទេ(ប្រយោគ ១១.១៣) តែភាគច្រើនបានប្រើប្រាស់ជា កិច្ចការផ្ទះ ជាលំហាត់ ឬគម្រោងផ្សេងៗ ដែលទាក់ទងនឹងជំពូកនោះ ដើម្បីធ្វើការវាយតម្លៃបញ្ចប់ជំពូកនោះ (ប្រយោគ ១១.៤)។

- ការវាយតម្លៃជាប្រចាំ

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានផ្តល់ប្រយោគចំនួន៤ប្រយោគដល់អ្នកចូលរួមជ្រើសរើស ដើម្បីបង្ហាញពីការអនុវត្តការវាយតម្លៃជាប្រចាំ (គ្រប់ម៉ោងបង្រៀន)។ លទ្ធផលបានបង្ហាញក្នុងតារាង ៤.២.៣ ខាងក្រោម។

**តារាង** 4.2. 3 **ភាគរយរបស់លោកគ្រូអ្នកគ្រូដែលបានជ្រើសរើសកម្រិតនីមួយៗចំពោះការវាយតម្លៃជាប្រចាំ**

| **ប្រយោគ** | | កម្រិតអនុវត្ត | | | | | |
|---|---|---|---|---|---|---|---|
| | | មិនបានអនុវត្ត | | | បានអនុវត្ត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **ការវាយតម្លៃជាប្រចាំ** ( **គ្រប់ម៉ោងបង្រៀន** ) | | | | | | | |
| 11.15 | ខ្ញុំសួរសំណួរផ្ទាត់មាត់ដើម្បីវាយតម្លៃនៅចុងបញ្ចប់ម៉ោងបង្រៀននីមួយៗ។ | 4.8 | 3.8 | 11.5 | 23.9 | 39.2 | 16.7 |
| 11.16 | ខ្ញុំដាក់លំហាត់ ឬ សំណួរឱ្យសិស្សឡើងធ្វើលើក្ដារខៀន ដើម្បីវាយតម្លៃនៅចុងបញ្ចប់ម៉ោងបង្រៀននីមួយៗ។ | 11.0 | 3.8 | 12.4 | 24.9 | 35.9 | 12.0 |
| 11.17 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សពិភាក្សាជាក្រុមតូចៗ (២ ទៅ ៥នាក់)។ | 7.2 | 11.0 | 20.6 | 23.0 | 25.4 | 12.9 |
| 11.18 | ខ្ញុំធ្វើការវាយតម្លៃដោយសម្ភាសសិស្ស ឬ ការសង្កេតមើលការសម្ភាសរវាងសិស្សនិងសិស្ស។ | 46.4 | 14.8 | 13.4 | 12.9 | 9.1 | 3.3 |
| 11.19 | ខ្ញុំធ្វើការវាយតម្លៃដោយការសង្កេតមើលលើការចូលរួមផ្សេងៗរបស់សិស្ស នៅក្នុងដំណើរការរៀនសូត្រ។ | 5.7 | 5.7 | 14.4 | 28.7 | 31.1 | 14.4 |
| 11.20 | ខ្ញុំធ្វើការវាយតម្លៃដោយសង្កេតមើលអន្តរកម្មរវាងសិស្ស និងសិស្ស ព្រមទាំងរវាងសិស្ស និងគ្រូ ក្នុងថ្នាក់រៀន។ | 8.6 | 6.7 | 14.8 | 25.8 | 32.5 | 11.5 |
| 11.21 | ខ្ញុំធ្វើការវាយតម្លៃដោយផ្អែកលើគម្រោងស្រាវជ្រាវផ្សេងៗ។ | 46.4 | 21.5 | 15.3 | 8.6 | 4.3 | 3.8 |
| 11.22 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សបង្កើតជារូបភាពផ្សេងៗ។ | 22.0 | 16.7 | 20.1 | 27.8 | 10.5 | 2.9 |
| 11.23 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សធ្វើបទបង្ហាញផ្សេងៗ។ | 15.3 | 15.8 | 18.2 | 23.0 | 23.9 | 3.8 |
| 11.24 | ខ្ញុំធ្វើការវាយតម្លៃដោយប្រើប្រាស់វីដេអូ ឬសំឡេងផ្សេងៗ។ | 51.2 | 19.6 | 5.7 | 12.9 | 8.6 | 1.9 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11.25 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សនិយាយសុន្ទរកថា ឬសេចក្តីថ្លែងការផ្សេងៗ។ | 60.8 | 10.0 | 9.6 | 6.7 | 9.6 | 3.3 |
| 11.26 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សធ្វើការពិសោធផ្សេងៗ។ | 24.4 | 22.5 | 18.2 | 14.4 | 14.4 | 6.2 |
| 11.27 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សសរសេររបាយការណ៍ផ្សេងៗ។ | 54.5 | 11.5 | 8.6 | 8.6 | 10.0 | 6.7 |
| 11.28 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សធ្វើការជជែកវែកញែក និងដេញដោលគ្នា។ | 33.5 | 18.2 | 13.4 | 13.9 | 13.4 | 7.7 |

* *[0 =មិនបានអនុវត្តសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

តារាងបង្ហាញថា មានលោកគ្រូអ្នកគ្រូប្រមាណជា ៨៩% និង ៧៣% បានអនុវត្តដូចទៅនឹងប្រយោគដែលបានលើកឡើងថា **«ខ្ញុំសួរសំណួរផ្ទាត់មាត់ដើម្បីវាយតម្លៃនៅចុងបញ្ចប់ម៉ោងបង្រៀននីមួយៗ។»** និង **«ខ្ញុំដាក់លំហាត់ ឬ សំណួរឱ្យសិស្សឡើងធ្វើលើក្តារខៀន ដើម្បីវាយតម្លៃនៅចុងបញ្ចប់ម៉ោងបង្រៀននីមួយៗ។»** (រៀងគ្នា)។ ហើយគ្រូក៏បានឯកភាពថា បានអនុវត្តផងដែរទៅលើប្រយោគ **«ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សពិភាក្សាជាក្រុមតូចៗ (២ ទៅ ៥នាក់)។»** ប៉ុន្តែមានលោកគ្រូអ្នកគ្រូប្រមាណជា ៤៦% មានបានរាយការណ៍ថា មិនបានអនុវត្តការវាយតម្លៃដោយសម្ភាសន៍សិស្ស ឬសង្កេតការសម្ភាសន៍រវាងសិស្សនិងសិស្សទេ(ប្រយោគ ១៣.១៩)។ យ៉ាងណាក៏មានលោកគ្រូអ្នកគ្រូមួយចំនួនបានប្រើប្រាស់វិធីវាយតម្លៃនេះដែរ។

ចំពោះប្រយោគ ***«ខ្ញុំធ្វើការវាយតម្លៃដោយការសង្កេតមើលលើការចូលរួមផ្សេងៗរបស់សិស្ស នៅក្នុងដំណើរការរៀនសូត្រ។»*** និង ***«ខ្ញុំធ្វើការវាយតម្លៃដោយសង្កេតមើលអន្តរកម្មរវាងសិស្ស និងសិស្ស ព្រមទាំងរវាងសិស្ស និងគ្រូ ក្នុងថ្នាក់រៀន។»*** មានលោកគ្រូអ្នកគ្រូប្រហែលជា ៧៤% និង ៧០% (រៀងគ្នា) បានបញ្ជាក់ថា បានអនុវត្ត ខណៈដែលមានប្រមាណជា ៥.៧% និង ៨.៦% (រៀងគ្នា) នៃគ្រូមិនបានអនុវត្តវិធីនេះទេ។ ចំពោះការវាយតម្លៃដោយប្រើ គម្រោងស្រាវជ្រាវ(ប្រយោគ ១១.២១) មានលោកគ្រូអ្នកគ្រូដល់ទៅ៤៦.៤% បានបង្ហាញថា ពួកគាត់មិនបានធ្វើទេ ខណៈមានតិចតួចដែលបានធ្វើ។ មានលោកគ្រូអ្នកគ្រូប្រមាណជា ៥៨.៨%និង ៤៨.៣% បានបញ្ជាក់ថា ពួកគាត់មិនបានអនុវត្តការវាយតម្លៃជាប្រចាំ ដោយឱ្យសិស្សបង្កើតជារូបភាពផ្សេងៗទេ និងដោយឱ្យសិស្សធ្វើបទបង្ហាញផ្សេងៗទេ(រៀងគ្នា) (ប្រយោគ ១១.២២ និង ១១.២៣)។

រីឯប្រយោគ ***«ខ្ញុំធ្វើការវាយតម្លៃដោយប្រើប្រាស់វីដេអូ ឬសំឡេងផ្សេងៗ។»*** និង ***«ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សនិយាយសុន្ទរកថាឬសេចក្តីថ្លែងការផ្សេងៗ។»*** មានគ្រូជាងពាក់កណ្តាល (៥១.២% និង ៦០.៨% រៀងគ្នា) បានជ្រើសរើសយក ***«មិនបានអនុវត្តសោះ»*** មានលោកគ្រូអ្នកគ្រូតិចតួចបានជ្រើសរើសកម្រិតអនុវត្តចាប់ពី៣ឡើងទៅ។ ចំពោះបីប្រយោគខាងក្រោយគេសម្រាប់ផ្នែកនេះ ដែលសួរអំពីការវាយតម្លៃដោយ ឱ្យសិស្សធ្វើការពិសោធផ្សេងៗ

ឱ្យសិស្សសរសេររបាយការណ៍ផ្សេងៗ និងឱ្យសិស្សធ្វើការជជែកវែកញែក និងដេញដោលគ្នាផ្សេងៗ លទ្ធផលបង្ហាញថា មានលោកគ្រូអ្នកគ្រូប្រហែលជា ២៤.៤%, ៥៤.៥%, និង ៣៣.៥% (រៀងគ្នា) បានបញ្ជាក់ថា មិនបានអនុវត្តទេ ដែលមានចំនួនតែប្រហាក់ប្រហែល ២០% ប៉ុណ្ណោះដែលបានជ្រើសរើសកម្រិតអនុវត្តចាប់ពីកម្រិត៣ឡើងទៅ។

ជារួមលទ្ធផលនៃបណ្តុំទី២ អាចសរុបបានថា ក្នុងពេលវាយតម្លៃបញ្ចប់ប្រចាំខែ(ប្រឡងប្រចាំខែ) លោកគ្រូអ្នកគ្រូបានភាគច្រើនបានប្រើវិញ្ញាផ្សេងៗគ្នាក្នុងកម្រិតថ្នាក់ដូចគ្នា ហើយនៅពេលតាក់តែងសំណួរតេស្តពួកគាត់មិនបានប្រើប្រាស់សៀវភៅសៀវភៅកម្មវិធីសិក្សាគោល និងសៀវភៅកម្មវិធីសិក្សាលម្អិតដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡានោះទេ។ បន្ថែមពីនេះទៀត លោកគ្រូ អ្នកគ្រូភាគច្រើនបានប្រើសំណួរតេស្តទម្រង់បើក(សំណួរតេស្តមានចម្លើយឱ្យសិស្សសរសេរ) ជាជាងទម្រង់បិទ(សំណួរតេស្តមានចម្លើយឱ្យសិស្សជ្រើសរើស) ក្នុងពេលតាក់តែងសំណួរតេស្ត ដោយសារតែសំណួរទម្រង់បិទជាទូទៅមិនសូវបានប្រើប្រាស់នៅពេលប្រឡងថ្នាក់ជាតិ។ ចំពោះយុទ្ធសាស្ត្រក្នុងការវាយតម្លៃបញ្ចប់មេរៀន និងជំពូកវិញ លោកគ្រូអ្នកគ្រូភាគច្រើនមិនបានប្រើប្រាស់កម្រងសំណួរតេស្តដើម្បីធ្វើការវាយតម្លៃនោះទេ គឺពួកគាត់បានធ្វើការវាយតម្លៃដោយដាក់កិច្ចការផ្ទះជាលំហាត់ជាដើម។ រីឯការវាយតម្លៃជាប្រចាំវិញ លោកគ្រូអ្នកគ្រូភាគច្រើនបានធ្វើការវាយតម្លៃដោយសួរផ្ទាល់មាត់ ដាក់ជាលំហាត់ ឬសំណួរឱ្យសិស្សឡើងធ្វើលើក្តារខៀន ឱ្យសិស្សពិភាក្សាជាក្រុមតូចៗ ខណៈដែលការវាយតម្លៃជាប្រចាំនេះមិនសូវបានផ្តោតលើការឱ្យសិស្សធ្វើកម្រោងស្រាវជ្រាវផ្សេងៗ បង្កើតរូបភាពផ្សេងៗ ធ្វើបទបង្ហាញ ប្រើវីដេអូ ឬសំឡេងផ្សេងៗ និយាយសន្ទនកថា សរសេររបាយការណ៍ស្រាវជ្រាវ ឬការជជែកវែកញែក និងដេញដោលគ្នាជាដើម។

## ៤.៣. បណ្តុំទី៣៖ ការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន

អ្នកស្រាវជ្រាវ បានប្រើប្រាស់ប្រយោគចំនួន២៨ ដើម្បីបង្ហាញពីយុទ្ធសាស្ត្រដែលលោកគ្រូអ្នកគ្រូបានធ្វើនៅពេលអនុវត្តការវាយតម្លៃកម្រិតថ្នាក់រៀន។ ក្នុងចំណោមប្រយោគទាំង២៨ អ្នកស្រាវជ្រាវបានចែកជាពីរបណ្តុំរងទៀត គឺ វិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន(មាន៦ប្រយោគ) និងបូកសរុបលទ្ធផលសិក្សាសិស្សក្នុងថ្នាក់រៀន(មាន៣ប្រយោគ) ដែលបង្ហាញជូនតាមលំដាប់លំដោយនៃតារាងខាងក្រោម (តារាង៤.៣.១ និង ៤.៣.២)។

- វិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានផ្តល់ប្រយោគចំនួន៦ប្រយោគដល់អ្នកចូលរួមជ្រើសរើស ដើម្បីបង្ហាញពីការប្រើប្រាស់ការវាយតម្លៃដោយវិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន។ លទ្ធផលបានបង្ហាញក្នុងតារាង ៤.៣.១ ខាងក្រោម។

**តារាង** 4.3. 1 **លទ្ធផលជ្រើសរើសរបស់គ្រូអំពីការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀនៈ វិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន**

| **ប្រយោគ** | | កម្រិតអនុវត្ត | | | | | |
|---|---|---|---|---|---|---|---|
| | | មិនបានអនុវត្ត | | | បានអនុវត្ត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **វិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន** | | | | | | | |
| 12.1 | ខ្ញុំវិភាគលទ្ធផលតាមសិស្សម្នាក់ៗ ដោយរកពិន្ទុសរុប និងមធ្យមភាគរបស់សិស្សម្នាក់ៗ។ | 4.3 | 7.2 | 9.1 | 20.1 | 27.8 | 31.6 |
| 12.2 | ខ្ញុំវិភាគលទ្ធផលតាមសំណួរនីមួយៗនិងរកភាគរយឆ្លើយត្រូវរបស់សំណួរនីមួយៗទាំងនោះ។ | 53.3 | 14.6 | 10.8 | 9.9 | 8.0 | 3.3 |
| 12.3 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីផ្តល់ព័ត៌មានត្រឡប់ឱ្យសិស្ស និងខ្លួនខ្ញុំផ្ទាល់។ | 0.0 | 4.3 | 7.7 | 16.3 | 39.2 | 32.5 |
| 12.4 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីវិភាគរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សឱ្យបានជាក់លាក់។ | 0.0 | 5.3 | 9.6 | 19.6 | 31.1 | 34.4 |
| 12.5 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីបែងចែករកសិស្សខ្លាំង សិស្សមធ្យម និងសិស្សខ្សោយ។ | 0.0 | 3.8 | 10.0 | 12.4 | 45.5 | 28.2 |
| 12.6 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនទៅវិភាគដើម្បីកែលម្អវិធីសាស្រ្តបង្រៀនរបស់ខ្ញុំ ក្នុងគោលបំណងជួយសិស្សខ្សោយ និងសិស្សមធ្យម។ | 0.0 | 3.3 | 5.7 | 16.7 | 42.1 | 32.1 |

* *[0 =មិនបានអនុវត្តសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

លទ្ធផលបង្ហាញថា មានលោកគ្រូអ្នកគ្រូភាគច្រើន (ប្រមាណជា ៨០% ដែលបានជ្រើសរើសកម្រិតអនុវត្តចាប់ពី ៣ ឡើងទៅ) បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដោយធ្វើការវិភាគលទ្ធផលតាមសិស្សម្នាក់ៗ ដោយរកពិន្ទុសរុប និងមធ្យមភាគរបស់សិស្សម្នាក់ៗ (ប្រយោគ ១២.១)។ ចំណុចគួរឱ្យចាប់អារម្មណ៍គឺ ថាមានលោកគ្រូអ្នកគ្រូជាងពាក់កណ្តាល (៥៣.៣%) បានប្រាប់ថា គាត់មិនបានធ្វើការវិភាគលទ្ធផលតាមសំណួរនីមួយៗ និងរកភាគរយឆ្លើយត្រូវរបស់សំណួរនីមួយៗទាំងនោះ (ប្រយោគ ១២.២)។ ប៉ុន្តែ ក៏មានចំនួនតិចតួចដែរ បានធ្វើដូចនេះ។

ជាងនេះទៅទៀត **មិនមាន**លោកគ្រូអ្នកគ្រូបានជ្រើសរើសយក “**មិនបានអនុវត្តសោះ**” ទៅលើប្រយោគ៤ខាងក្រោមគេបង្អស់នៅក្នុងផ្នែកនេះទេ ផ្ទុយទៅវិញ គ្រូភាគច្រើនបានបញ្ជាក់ពីការបានអនុវត្តទៅលើសកម្មភាពទាំង

នេះ។ ចំពោះប្រយោគ *"ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីផ្តល់ព័ត៌មានត្រឡប់ឱ្យសិស្ស និងខ្លួនខ្ញុំផ្ទាល់។" "ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីវិភាគរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សឱ្យបានជាក់លាក់។" "ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីបែងចែករកសិស្សខ្លាំង សិស្សមធ្យម និងសិស្សខ្សោយ។"* និង *"ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនទៅវិភាគដើម្បីកែលម្អវិធីសាស្ត្របង្រៀនរបស់ខ្ញុំ ក្នុងគោលបំណងជួយសិស្សខ្សោយ និងសិស្សមធ្យម។"* មានលោកគ្រូអ្នកគ្រូប្រមាណជា ៨៨%, ៨៥%, ៨៦%, និង៩១% (រៀងគ្នា) បានជ្រើសរើសកម្រិតអនុវត្តចាប់ពីលេខ៣ឡើងទៅ ដែលជាការបង្ហាញថា ពួកគាត់ភាគច្រើនបានអនុវត្តសកម្មភាពទាំងអស់នេះ។

- បូកសរុបលទ្ធផលសិក្សាសិស្សក្នុងថ្នាក់រៀន

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានផ្តល់ប្រយោគចំនួន៣ប្រយោគដល់អ្នកចូលរួមជ្រើសរើស ដើម្បីបង្ហាញពីការប្រើប្រាស់ការវាយតម្លៃដើម្បីបូកសរុបលទ្ធផលសិក្សាសិស្សក្នុងថ្នាក់រៀន។ លទ្ធផលបានបង្ហាញក្នុងតារាង ៤.៣.២ ខាងក្រោម។

**តារាង** 4.3. 2 **លទ្ធផលជ្រើសរើសរបស់គ្រូអំពីការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន៖ បូកសរុបលទ្ធផលសិក្សាសិស្សក្នុងថ្នាក់រៀន**

| **ប្រយោគ** | | កម្រិតអនុវត្ត | | | | | |
|---|---|---|---|---|---|---|---|
| | | មិនបានអនុវត្ត | | | បានអនុវត្ត | | |
| | | 0 | 1 | 2 | 3 | 4 | 5 |
| **បូកសរុបលទ្ធផលសិក្សាសិស្សក្នុងថ្នាក់រៀន** | | | | | | | |
| 12.7 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីបូកសរុបពិន្ទុប្រគល់ជូនសាលារៀន។ | 2.4 | 5.3 | 3.8 | 13.4 | 34.9 | 40.2 |
| 12.8 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីធ្វើចំណាត់ថ្នាក់ជ្រើសរើសសិស្សពូកែក្នុងថ្នាក់រៀន។ | 1.9 | 2.4 | 2.9 | 21.5 | 32.5 | 38.8 |
| 12.9 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីធ្វើការប្រៀបធៀបលទ្ធផលរវាងថ្នាក់មួយនិងថ្នាក់មួយទៀត។ | 5.7 | 4.8 | 12.0 | 20.6 | 38.8 | 18.2 |

* *[0 =មិនបានអនុវត្តសោះ], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]*

លទ្ធផលក្នុងតារាង ៤.៧ បង្ហាញថាមានលោកគ្រូអ្នកគ្រូប្រមាណជា ៨៨.៥% បានជ្រើសរើសកម្រិតអនុវត្តចាប់ពីលេខ៣ឡើងទៅ ចំពោះប្រយោគ *"ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីបូកសរុបពិន្ទុប្រគល់ជូនសាលារៀន។"* ខណៈដែលមាន២.៤%ថា គាត់មិនដែលបានអនុវត្តដូចនេះសោះ។ ក៏មានលោកគ្រូអ្នកគ្រូ

ភាគច្រើនបានប្រើប្រាស់លទ្ធផលរបស់ការវាយតម្លៃផ្សេងៗ ដើម្បីធ្វើចំណាត់ថ្នាក់ផ្សេងៗដែរ។ ជាឧទាហរណ៍ មានគ្រូប្រហែលជា ៩៣% បានបញ្ជាក់ថា បានអនុវត្តសកម្មភាពដូចក្នុងប្រយោគ ***"ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីធ្វើចំណាត់ថ្នាក់ជ្រើសរើសសិស្សពូកែក្នុងថ្នាក់រៀន។"*** ។ ខណៈ មានគ្រូបង្រៀនប្រហែលជា ៧៧.៦% បានជ្រើសរើសកម្រិតអនុវត្តចាប់ពីលេខ៣ដល់លេខ៥ ទៅលើប្រយោគ "ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីធ្វើការប្រៀបធៀបលទ្ធផលរវាងថ្នាក់មួយនិងថ្នាក់មួយទៀត។" តែក៏មានគ្រូប្រមាណជា ៥.៧%ដែរ ដែលមិនបានអនុវត្តដូច្នេះ។

តាមតាមលទ្ធផលបណ្តុំទី៣ដែលបានបង្ហាញខាង អាចសរុបជារួមបានថា លោកគ្រូអ្នកគ្រូភាគច្រើន យកលទ្ធផលដែលទទួលបានពីការវាយតម្លៃដើម្បីផ្តល់ព័ត៌មានត្រឡប់ជូនសិស្ស និងខ្លួនគាត់ផ្ទាល់ វិភាគរកចំណុចខ្លាំង និងចំណុចខ្សោយសិស្សឱ្យបានជាក់លាក់ បែងចែកសិស្សខ្សោយ សិស្សមធ្យម និងសិស្សពូកែ ថែមទាំងយកលទ្ធផលដែលទទួលបានទៅកែលម្អវិធីសាស្ត្របង្រៀនរបស់គាត់ទៀតផង។ មិនតែប៉ុណ្ណោះពួកគាត់ក៏បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះដើម្បីបូកសរុបពិន្ទុជូនសាលា និងធ្វើការប្រៀបធៀបលទ្ធផលសិក្សាសិស្សពីថ្នាក់មួយទៅថ្នាក់មួយទៀត ខណៈដែលពួកគាត់មិនបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះដើម្បីវិភាគលទ្ធផលតាមសំណួរនីមួយៗ និងរកភាគរយឆ្លើយត្រូវសំណួរនីមួយៗនោះដើម្បីរកគុណភាពនៃសំណួរតេស្តនោះទេ។

# ជំពូក៥

# សរុបលទ្ធផល សន្និដ្ឋាន និងអនុសាសន៍

ជំពូកនេះ អ្នកស្រាវជ្រាវធ្វើការពិភាក្សាចំណុចគន្លឹះសំខាន់ដែលបានរកឃើញ និងធ្វើសេចក្តីសន្និដ្ឋាន ព្រមទាំងផ្តល់អនុសាសន៍សម្រាប់ការរៀបចំគោលនយោបាយ និងស្រាវជ្រាវបន្ត។

## ៥.១ សរុបលទ្ធផល

ការសិក្សានេះមានគោលបំណង ដើម្បីពិនិត្យមើលពីការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនៅកម្រិតថ្នាក់រៀន ការយល់ឃើញ និងយុទ្ធសាស្ត្រនៃការវាយតម្លៃរបស់លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀននៅសាលាវិទ្យាល័យនៅក្នុងខេត្តកំពង់ធំ ចំពោះការអនុវត្តការវាយតម្លៃទាំងនេះ។ នៅក្នុងនេះផងដែរអ្នកស្រាវជ្រាវ បានជ្រើសរើសភាគសំណាកគ្រូចំនួនសរុប ២១០ នាក់ ស្រីចំនួន ៩៦ នាក់ មកពីសាលាចំនួន១០ ក្នុងស្រុកបារាយណ៍ ស្ទឹងសែនស្ទោង និងស្រុកសន្ទុក ក្នុងខេត្តកំពង់ធំ។ ឧបករណ៍ស្រាវជ្រាវ អ្នកស្រាវជ្រាវ បានប្រើកម្រងសំណួរទម្រង់បើកចំនួន ៤៨សំណួរដោយចែកជាបីបណ្តុំធំៗ៖ បណ្តុំទី១ ទស្សនៈរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន (សំណួរទី ១០.១ ដល់ ១០.១១) បណ្តុំទី២ យុទ្ធសាស្ត្រក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន (សំណួរទី ១១.១ ដល់ សំណួរ ១១.២៨) និងបណ្តុំទី៣ ការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន(សំណួរទី ១២.១ ដល់ ១២.៩)។ ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបរិមាណវិស័យ។ ។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី WINDEM ដើម្បីបញ្ចូល និងគ្រប់គ្រងទិន្នន័យ និងប្រើកម្មវិធី SPSS សម្រាប់ស្វែងរកចំនួនប្រេកង់គិតជាភាគរយ និង Microsoft Excel តារាង និងបកស្រាយព័ត៌មាន។

លទ្ធផលនៃការស្រាវជ្រាវអាចសរុបបានដូចខាងក្រោម៖

១. លោកគ្រូអ្នកគ្រូដែលបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ធំ ពេញចិត្តចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន ហើយពួកគាត់គិតថាដំណើរការវាយតម្លៃនេះពិតជាមានសារៈសំខាន់ដើម្បីការបង្រៀន និងរៀន មានគុណភាព។

២. ក្នុងពេលវាយតម្លៃបញ្ចប់ប្រចាំខែ(ប្រឡងប្រចាំខែ) លោកគ្រូ អ្នកគ្រូបានភាគច្រើនបានប្រើវិញ្ញាផ្សេងៗគ្នាក្នុងកម្រិតថ្នាក់ដូចគ្នា ហើយនៅពេលគាត់តែងសំណួរតេស្ត ពួកគាត់មិនបានប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោល និងសៀវភៅកម្មវិធីសិក្សាលម្អិតដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡានោះទេ។ បន្ថែមពីនេះទៀត លោកគ្រូ អ្នកគ្រូភាគច្រើនបានប្រើសំណួរតេស្តទម្រង់បើក(សំណួរតេស្តមានចម្លើយឱ្យសិស្សសរសេរ) ជាជាងទម្រង់បិទ(សំណួរតេស្តមានចម្លើយឱ្យសិស្សជ្រើសរើស) ក្នុងពេលគាត់តែងសំណួរតេស្ត ដោយសារតែសំណួរទម្រង់បិទជាទូទៅមិនសូវបានប្រើប្រាស់នៅពេលប្រឡងថ្នាក់ជាតិ។ ចំពោះ យុទ្ធសាស្ត្រក្នុងការវាយតម្លៃបញ្ចប់មេរៀន និង

ជំពូកវិញ លោកគ្រូអ្នកគ្រូភាគច្រើនមិនបានប្រើប្រាស់កម្រងសំណួរតេស្តដើម្បីធ្វើការវាយតម្លៃនោះទេ គឺពួកគាត់បានធ្វើការវាយតម្លៃដោយដាក់កិច្ចការផ្ទះជាលំហាត់ជាដើម។ រីឯការវាយតម្លៃជាប្រចាំវិញ លោកគ្រូអ្នកគ្រូភាគច្រើនបានធ្វើការវាយតម្លៃដោយសួរផ្ទាល់មាត់ ដាក់ជាលំហាត់ ឬសំណួរ ឱ្យសិស្សឡើងធ្វើលើក្តារខៀន ឱ្យសិស្សពិភាក្សាជាក្រុមតូចៗ ខណៈដែលការវាយតម្លៃជាប្រចាំនេះមិនសូវបានផ្តោតលើឱ្យសិស្សធ្វើកម្រោងស្រាវជ្រាវផ្សេងៗ បង្កើតរូបភាពផ្សេងៗ ធ្វើបទបង្ហាញ ប្រើវីដេអូ ឬសំឡេងផ្សេងៗ និយាយសន្ទរកថា សរសេររបាយការណ៍ស្រាវជ្រាវ ឬការជជែកវែកញែក និងដេញដោលគ្នាជាដើម។

៣. លោកគ្រូអ្នកគ្រូភាគច្រើន យកលទ្ធផលដែលទទួលបានពីការវាយតម្លៃដើម្បីផ្តល់ព័ត៌មានត្រឡប់ជូនសិស្ស និងខ្លួនគាត់ផ្ទាល់ វិភាគរកចំណុចខ្លាំង និងចំណុចខ្សោយសិស្សឱ្យបានជាក់លាក់ បែងចែកសិស្សខ្សោយ សិស្សមធ្យម និងសិស្សពូកែ ថែមទាំងយកលទ្ធផលដែលទទួលបានទៅកែលម្អវិធីសាស្ត្របង្រៀនរបស់គាត់ទៀតផង។ មិនតែប៉ុណ្ណោះពួកគាត់ក៏បានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះដើម្បីបូកសរុបពិន្ទុជូនសាលា និងធ្វើការប្រៀបធៀបលទ្ធផលសិក្សាសិស្សពីថ្នាក់មួយ ទៅថ្នាក់មួយទៀត ខណៈដែលពួកគាត់មិនបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះដើម្បីវិភាគលទ្ធផលតាមសំណួរនីមួយៗ និងរកភាគរយឆ្លើយត្រូវសំណួរនីមួយៗនោះដើម្បីរកគុណភាពនៃសំណួរតេស្តនោះទេ។

## ៥.២ សេចក្តីសន្និដ្ឋាន

ជារួមការសិក្សានេះបង្ហាញថា គ្រូបង្រៀនភាគច្រើនលើសលុបមានឥរិយាបថវិជ្ជមានចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន និងបានគិតថា ការវាយតម្លៃកម្រិតថ្នាក់រៀនពិតជាមានសារៈសំខាន់សម្រាប់ជំរុញគុណភាពអប់រំជាការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព។ ប៉ុន្តែ ចំពោះការប្រើប្រាស់យុទ្ធវិធីក្នុងការវាយតម្លៃហាក់នៅមានកម្រិត។

លទ្ធផលបានបង្ហាញថា គ្រូភាគច្រើនបានមិនប្រើប្រាស់ ឬប្រើប្រាស់តិចតួច នូវសៀវភៅកម្មវិធីសិក្សាគោល និងសៀវភៅកម្មវិធីសិក្សាលម្អិត ដែលរៀបរៀងដោយក្រសួងអប់រំ យុវជន និងកីឡា នៅពេលរៀបចំវិញ្ញាសាប្រឡងប្រចាំខែ មិនបានរៀបចំជាគម្រោងលម្អិតតេស្តមុនពេលចាប់ផ្តើមតាក់តែងសំណួរតេស្ត។ **នេះបញ្ជាក់ថា គ្រូបង្រៀនធ្វើការវាយតម្លៃប្រចាំខែកម្រិតថ្នាក់រៀនមិនបានផ្តោតសំខាន់លើកម្មវិធីសិក្សាថ្នាក់ជាតិទេ។**

គ្រូបង្រៀនក៏មិនបានប្រើ ឬបានប្រើសំណួរទម្រង់ពហុជ្រើសរើសតតិចតួចក្នុងពេលធ្វើការវាយតម្លៃដោយសារទម្រង់សំណួរនេះមិនមានប្រើនៅក្នុងវិញ្ញាសារប្រឡងមធ្យមសិក្សាទុតិយភូមិ ជាជាងដែលថាពួកគាត់មិនបានចេះបង្កើតសំណួរប្រភេទនេះ ដោយភាគច្រើនប្រើតែសំណួរទម្រង់បើក។ **នេះបញ្ជាក់ថា នៅកម្រិតថ្នាក់រៀនសិស្សហាក់មិនសាំជាមួយការវាយតម្លៃ ឬប្រឡងដោយប្រើសំណួរដែលមានទម្រង់ចម្រុះនោះទេ។**

គ្រូបង្រៀនបានបញ្ជាក់ថា មិនបានប្រើវិញ្ញាសាតែមួយដូចគ្នា ដើម្បីធ្វើការវាយតម្លៃប្រចាំខែ ឬមានតិចតួចប៉ុណ្ណោះដែលបានប្រើ។ **នេះបង្ហាញថា គ្រូបង្រៀនដែលមានមុខវិជ្ជាដូចគ្នា ហើយសូម្បីតែបង្រៀននៅក្នុងកម្រិតថ្នាក់ដូចគ្នាក៏ដោយ មិនបានធ្វើការរួមគ្នាដើម្បីបង្កើតវិញ្ញាសាសម្រាប់ឱ្យសិស្សរបស់គាត់បានធ្វើដូចគ្នានោះទេ។**

នៅពេលគាត់តែងសំណួរតេស្ត គ្រូភាគច្រើនបានគិតដល់កម្រិតពុទ្ធិ តាមទ្រឹស្តីបទប្លូម (Bloom's Taxonomy) នៃសំណួរ ដូចជាកម្រិតចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។ **នេះបញ្ជាក់ថា គ្រូបានស្គាល់ និងប្រើប្រាស់កម្រិតពុទ្ធិតាមទ្រឹស្តីប្លូមក្នុងកម្រិតថ្នាក់រៀន។**

តែយ៉ាងណាក៏ដោយ ក៏មានគ្រូបង្រៀនភាគច្រើនបានបញ្ជាក់ថា ពួកគាត់មិនបានប្រើ ឬប្រើតិចតួចនូវវិធីផ្សេងៗ ទៀតដូចជា ឱ្យសិស្សនិយាយសុន្ទរកថា ឬសេចក្តីថ្លែងការផ្សេងៗ ឱ្យសិស្សសរសេររបាយការណ៍ផ្សេងៗ ប្រើប្រាស់វីដេអូ ឬសំឡេងផ្សេងៗ សម្ភាសន៍សិស្ស ឬការសង្កេតមើលការសម្ភាសន៍រវាងសិស្សនិងសិស្ស ឱ្យសិស្សធ្វើកិច្ចការគម្រោងស្រាវជ្រាវផ្សេងៗ ឱ្យសិស្សធ្វើការជជែកវែកញែក និងដេញដោលគ្នា ឱ្យសិស្សធ្វើការពិសោធផ្សេងៗ ឱ្យសិស្សបង្កើតជារូបភាពផ្សេងៗ ឬដោយឱ្យសិស្សធ្វើបទបង្ហាញផ្សេងៗទេ ដែលមធ្យោបាយទាំងនេះបង្ហាញពីសមត្ថភាពសិស្សក្នុងការអនុវត្តផ្សេងៗ ហើយភាគច្រើនពួកគាត់បានប្រើជាសំណួរផ្ទាល់មាត់ ឱ្យសិស្សឡើងឆ្លើយឬធ្វើលំហាត់លើក្តារខៀនជាដើម។ **នេះបង្ហាញថា លោកគ្រូអ្នកគ្រូបានធ្វើការវាយតម្លៃកម្រិតថ្នាក់រៀនដោយមិនបានផ្តោតលើសមត្ថភាព**( competency-based assessment ) **ឬលទ្ធផលសិក្សារបស់សិស្ស**( performance-based assessment )**ទេ ពួកគាត់ដោយផ្តោតតែទៅលើចំណេះដឹងរបស់សិស្សប៉ុណ្ណោះ។**

តែយ៉ាងណាក៏ដោយ លោកគ្រូអ្នកគ្រូភាគច្រើនបានបង្ហាញថាពួកគាត់បាន ធ្វើការវិភាគលទ្ធផលតាមសិស្សម្នាក់ៗ ដោយរកពិន្ទុសរុប និងមធ្យមភាគរបស់គាត់ ដើម្បីយកពិន្ទុជូនសាលា និងស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សឱ្យបានជាក់លាក់ ព្រមទាំងដើម្បីផ្តល់ព័ត៌មានត្រឡប់ឱ្យសិស្ស និងខ្លួនគាត់ផ្ទាល់ដើម្បីកែលម្អវិធីសាស្ត្របង្រៀន ក្នុងគោលបំណងជួយសិស្សខ្សោយ និងសិស្សមធ្យម និងក្នុងគោលបំណងដើម្បីបែងចែករកសិស្សខ្លាំង សិស្សមធ្យម និងសិស្សខ្សោយ។ ប៉ុន្តែ លោកគ្រូអ្នកគ្រូភាគច្រើន បានបញ្ជាក់ថា មិនបានធ្វើឬមានគ្រូតិចតួចបានធ្វើការវិភាគលទ្ធផលតាមសំណួរនីមួយៗ និងរកភាគរយឆ្លើយត្រូវរបស់សំណួរនីមួយៗទាំងនោះដើម្បីបង្ហាញពីគុណភាពរបស់សំណួរតេស្ត។ **ចំណុចនេះឆ្លុះបញ្ចាំងថា លោកគ្រូអ្នកគ្រូបានប្រើប្រាស់លទ្ធផលពីការវាយតម្លៃគោលបំណងច្រើនប្រភេទ ប៉ុន្តែមិនទាន់បានប្រើប្រាស់លទ្ធផលនេះដើម្បីកំណត់រកពីគុណភាពសំណួរតេស្ត និងវិញ្ញាសាទេ និងមិនបានអនុវត្តតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានសំណូមពរឱ្យលោកគ្រូអ្នកគ្រូធ្វើការវិភាគលទ្ធផលតាមសំណួរនីមួយៗ។**

**លទ្ធផលនេះបង្ហាញថា បើទោះជាលោកគ្រូអ្នកគ្រូមានឥរិយាបថវិជ្ជមានចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន និងបានគិតថាការវាយតម្លៃកម្រិតថ្នាក់រៀនពិតជាមានសារៈសំខាន់សម្រាប់ជំរុញគុណភាពនៃការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព ប៉ុន្តែមានចំណុចប្រឈមជាច្រើនដែលត្រូវជំរុញបន្ថែមដូចជា ការប្រើយុទ្ធវិធីឱ្យ**

កាន់តែចម្រុះ ការអនុវត្តបន្ថែមនៃការវាយតម្លៃផ្អែកលើសមត្ថភាពនិងលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងការប្រើប្រាស់លទ្ធផលពីការវាយតម្លៃឱ្យកាន់តែទូលំទូលាយ។

## ៥.៣ អនុសាសន៍

### ៥.៣.១ អនុសាសន៍សម្រាប់ការអនុវត្ត

- ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នានឹងកម្មវិធីវាយតម្លៃផ្សេងទៀតដូចគ្នា ការវាយតម្លៃកម្រិតសាលារៀន និងថ្នាក់ជាតិ សាលានិងក្រសួងគួរជំរុញលោកគ្រូអ្នកគ្រូឱ្យរៀបចំការវាយតម្លៃប្រចាំខែឱ្យពិនិត្យដោយផ្អែកលើកម្មវិធីសិក្សាថ្នាក់ជាតិផងដែរ។
- សាលារៀននិងក្រសួងគួរមានជំរុញឱ្យលោកគ្រូអ្នកគ្រូប្រើទម្រង់សំណួរចម្រុះដើម្បីឱ្យសិស្សបានអនុវត្តច្រើន និងអាចធ្វើបានទៅតេស្តថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។
- សាលាមិនគួរប្រើធ្វើការប្រៀបធៀបលទ្ធផលការងាររបស់បង្រៀនរបស់គ្រូទាំងពីរ ឬបីនេះបានទេ។ តែបើចង់ធ្វើការប្រៀបធៀប សាលារៀននិងថ្នាក់ដឹកនាំផ្សេងទៀត ត្រូវជំរុញឱ្យគ្រូដែលបង្រៀនមុខវិជ្ជាដូចគ្នាក្នុងកម្រិតថ្នាក់តែមួយប្រើវិញ្ញាសារួមគ្នា។
- ក្រសួងនិងសាលារៀនគួរជំរុញលោកគ្រូអ្នកគ្រូបន្ថែមអនុវត្តការវាយតម្លៃដោយផ្អែកលើសមត្ថភាព និងលទ្ធផលសិក្សារបស់សិស្សឱ្យច្រើនទៀតដើម្បីឆ្លើយតបនឹងគោលដៅជាតិដែលចង់បានធនធានមនុស្សដែលមានកម្រិតជំនាញខ្ពស់ទៅថ្ងៃអនាគត។
- ក្រសួងនិងសាលារៀន គួរជំរុញបន្ថែមនូវការអនុវត្តការណែនាំឱ្យបានកាន់តែទូលំទូលាយអំពីសំពីសំណួមពរឱ្យលោកគ្រូអ្នកគ្រូធ្វើការវិភាគលទ្ធផលតាមសំណួរនីមួយៗ ដើម្បីសម្រាប់បានគោលបំណងអប់រំជាតិ។

### ៥.៣.២ អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត

ការសិក្សានេះផ្តោតលើការវាយតម្លៃកម្រិតថ្នាក់រៀនៈទស្សនៈ ការប្រើប្រាស់ និងយុទ្ធសាស្ត្រ របស់លោកគ្រូអ្នកគ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ធំ ហើយសម្រាប់អ្នកស្រាវជ្រាវដទៃទៀត អាចពិចារណាដូចតទៅៈ

- សិក្សាលើការវាយតម្លៃកម្រិតថ្នាក់រៀនគ្រូបង្រៀននៅបឋមសិក្សា និងនៅមធ្យមសិក្សាបឋមភូមិ ដែលមាននៅក្នុងខេត្តកំពង់ធំដដែល ឬខេត្តដទៃទៀត។
- សិក្សាឱ្យបានស៊ីជំរៅចំពោះលោកគ្រូអ្នកគ្រូដែលបានអះអាងថា នៅពេលគាត់តែងសំណួរតេស្ត គ្រូភាគច្រើនបានគិតដល់កម្រិតពុទ្ធិ តាមទ្រឹស្តីបទប្លូម (Bloom's Taxonomy) នៃសំណួរ ដូចជាកម្រិតចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី ខណៈដែលតាមការអង្កេតជាក់ស្តែង មានគ្រូបង្រៀនមួយចំនួនតូចប៉ុណ្ណោះដែលមានការយល់ដឹងទ្រឹស្តីប្លូម។

# ឯកសារយោង

Alaba Adeyemi Adediwura. (2012). Teachers׳ Perception of School-Based Assessment in Nigerian Secondary Schools. Vol.3.

LOUIS COHEN, LAWRENCE MANION, & KEITH MORRISON. (2007). Research Methods in Education.

MoEYS. (2007a). គំរូកិច្ចការវាយតម្លៃ មុខវិជ្ជាគណិតវិទ្យា.

MoEYS. (2007b). គំរូកិច្ចការវាយតម្លៃ មុខវិជ្ជាភាសាខ្មែរ.

MoEYS. (2007c). គំរូកិច្ចការវាយតម្លៃ មុខវិជ្ជាវិទ្យាសាស្ត្រ.

MoEYS. (2007d). គំរូកិច្ចការវាយតម្លៃ មុខវិជ្ជាវិទ្យាសាស្ត្រសង្គម.

MoEYS. (2014). EDUCATION STRATEGIC PLAN 2014-2018.

MoEYS. (2015). CURRICULUM FRAMEWORK OF GENERAL EDUCATION AND TECHNICAL EDUCATIO.

MoEYS. (2016). STUDENT ASSESSMENT.

MoEYS. (2017). Results of Grade Six Student Achievement from the National Assessment in 2016.

MoEYS. (2018a). K-12 Student Learning Assessment Framework. EQAD.

MoEYS. (2018b). Results of Grade 8 Student Achievement from the National Assessment in 2017.

MoEYS. (2019). ស្ថិតិ និងសូចនាករអប់រំ.

Muhammad Saeed, HafsaTahir, & Iqra Latif. (2018). Teachers׳ Perceptions about the Use of Classroom Assessment Techniques in Elementary and Secondary Schools. 40.

Richard, G., & Jonathan, A. (2012). Classroom Assessment Preferences of Japanese Language Teachers in the Philippines and English Language Teachers in Japan. MEXTESOL Journal, 36.

Sayed Ahmad Javid Mussawy. (2009). Assessment Practices: Student׳s and Teachers׳ Perceptions of Classroom Assessment.

Tajularipin Sulaiman, Suzieleez Syrene Abdul Rahim, Muhammad Nazrul Hakim, & Rosmaria Omar. (2019). Teachers׳ Perspectives of Assessment and Alternative Assessment in the Classroom. Vol.8(7S2).

Yuankun Yao. (2015). Teacher Perceptions of Classroom Assessment: A focus group interview. Vol.24, 51.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខ [illegible] អយក.វិក

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង ៖** កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៩១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១១៩ វជអ.ករ

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡុងទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត ព៌ុជ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា គត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៊ុម សុគា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាវស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈឿន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណ្ណ | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណារ៉ា**

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

**ឧបសម្ព័ន្ធទី ២៖ កម្រងសំណួរ**

## កម្រងសំណួរសម្រាប់គ្រូបង្រៀន

ខ្ញុំបាទឈ្មោះ **អុន សេងទ្រី** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទបញ្ចប់ការសិក្សាលើប្រធានបទ "**ការវាយតម្លៃការសិក្សាកម្រិតថ្នាក់រៀន (ទស្សនៈ ការប្រើប្រាស់ និងយុទ្ធសាស្ត្ររបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ**)" ដែលដឹកនាំការស្រាវជ្រាវដោយសាស្ត្រាចារ្យបណ្ឌិត **ម៉ុក សារ៉ុម** ។

អាស្រ័យហេតុនេះសូមលោកគ្រូ អ្នកគ្រូជួយផ្តល់ចម្លើយ ***ឱ្យបានសុក្រឹត*** លើកម្រងសំណួរស្រាវជ្រាវអប់រំដោយក្តីអនុគ្រោះ។ កម្រងសំណួរនេះមានគោលបំណង៖

- ស្វែងយល់ពីទស្សនៈរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតថ្នាក់រៀន
- ពិនិត្យមើលពីយុទ្ធសាស្ត្រផ្សេងៗដែលលោកគ្រូ អ្នកគ្រូដើម្បីធ្វើការវាយតម្លៃនៅកម្រិតថ្នាក់រៀន
- កំណត់រកការប្រើប្រាស់លទ្ធផលបានមកពីការវាយតម្លៃការសិក្សារបស់សិស្សកម្រិតថ្នាក់រៀន ។

គ្រប់ចម្លើយរបស់លោកគ្រូ អ្នកគ្រូនឹងត្រូវរក្សាជា ***ការសម្ងាត់*** ដោយមិនធ្វើការវិនិច្ឆ័យសាលារៀន ឬតិះទៀនគ្រូបង្រៀន ឬនាយក-នាយិកានោះឡើយ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងផ្តល់ចម្លើយដ៏ក្បោះក្បាយរបស់លោកគ្រូ អ្នកគ្រូ។

## ផ្នែកទី១៖ ព័ត៌មានទូទៅរបស់អ្នកចូលរួម

***ការណែនាំ៖*** *សូមគូសសញ្ញា √ ក្នុងប្រអប់ □ ជាមួយស្ថានភាពទូទៅរបស់លោកគ្រូ អ្នកគ្រូ។ សម្រាប់ឈ្មោះសាលា ឈ្មោះស្រុក និងលេខទូរស័ព្ទ សូមបំពេញក្នុងបន្ទាត់ដាច់ៗខាងក្រោម ។*

1. ឈ្មោះវិទ្យាល័យ៖ ...........................................ស្រុក៖ ................................ ខេត្ត៖ កំពង់ធំ។
   លេខទូរស័ព្ទទំនាក់ទំនង៖ ........................................./.....................................................
2. ភេទ៖ □1. ប្រុស □2. ស្រី
3. អាយុ៖ □1. 20 – 25 ឆ្នាំ □2. 26 – 30 ឆ្នាំ □3. 31 ឆ្នាំឡើង
4. មុខវិជ្ជាបង្រៀន៖ □1. ភាសាខ្មែរ □2. គណិតវិទ្យា □3. វិទ្យាសាស្ត្រពិត □4. វិ.សង្គម □5. ភាសាអង់គ្លេស □6. ផ្សេងៗ ............
5. ចំនួនមុខវិជ្ជាកំពុងបង្រៀន៖
   □1. ១ មុខវិជ្ជា □2. ២ មុខវិជ្ជា □3. ៣ មុខវិជ្ជា □4. ច្រើនជាង ៣ មុខវិជ្ជា
6. ចំនួនកម្រិតថ្នាក់កំពុងបង្រៀន៖
   □1. ១ កម្រិតថ្នាក់ □2. ២ កម្រិតថ្នាក់ □3. ៣ កម្រិតថ្នាក់ □4. ច្រើនជាង ៣
7. បទពិសោធន៍បង្រៀន៖
   □1. ១ ដល់ ៥ ឆ្នាំ □2. ៦ ដល់ ១០ឆ្នាំ □3. ច្រើនជាង ១០ឆ្នាំ
8. សញ្ញាបត្រទទួលបានខ្ពស់បំផុត៖

| | |
|---|---|
| □1 | ទាបជាងបរិញ្ញាបត្រ |
| □2 | បរិញ្ញាបត្រ |
| □3 | អនុបណ្ឌិត |
| □4 | បណ្ឌិត |

9. កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈខ្ពស់បំផុត៖

| | |
|---|---|
| □1 | គ្រូកម្រិតបឋម (៩+១ ឬ៩+២ ឬ១២+២ ឬក្រៅពីនេះ) |
| □2 | គ្រូកម្រិតមូលដ្ឋាន (៩+១ ឬ៩+២ ឬ ១២+២ ឬក្រៅពីនេះ) |
| □3 | គ្រូកម្រិតឧត្តម (បរិញ្ញាបត្រ+១) |
| □4 | ផ្សេងទៀត(បញ្ជាក់៖...............................................) |

## ផ្នែកទី២៖ ការវាយតម្លៃការសិក្សាកម្រិតថ្នាក់រៀន

## ១. ទស្សនៈរបស់លោកគ្រូ អ្នកគ្រូនៅលើការវាយតម្លៃកម្រិតថ្នាក់រៀន

***ការណែនាំ៖*** *ផ្នែកនេះមាន ១១ សំណួរសម្រាប់គូស។*

*សូមពិចារណា ខ្លឹមសារសំណួរនីមួយៗដូចខាងក្រោម ហើយជ្រើសរើសយកចម្លើយដោយគូសសញ្ញា √ ទៅក្នុងចន្លោះតែមួយគត់ នៅក្នុងតារាងឱ្យត្រូវ**តាមការពិតជាក់ស្តែង** និង**តាមការអនុវត្តរបស់លោកគ្រូ អ្នកគ្រូ**។*

10. **តើលោកគ្រូ អ្នកគ្រូយល់ឃើញដូចម្តេចខ្លះចំពោះការវាយតម្លៃទាំងអស់នោះ?**

[0 =មិនបានអនុវត្ត], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]

| ល.រ | ទស្សនៈរបស់លោកគ្រូអ្នកគ្រូចំពោះការវាយតម្លៃកម្រិតថ្នាក់រៀន | មិនយល់ស្រប | យល់ស្រប (ក្នុងកម្រិតខាងក្រោម) | | | | |
|---|---|---|---|---|---|---|---|
| | | 0 | 1 | 2 | 3 | 4 | 5 |
| **ឥរិយាបថក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន** | | | | | | | |
| 10.1 | ខ្ញុំចូលចិត្តធ្វើការវាយតម្លៃកម្រិតថ្នាក់រៀន ព្រោះវាអាចជួយឱ្យខ្ញុំរកឃើញនូវសិស្សខ្លាំង មធ្យម និងខ្សោយ។ | | | | | | |
| 10.2 | ខ្ញុំចូលចិត្តធ្វើការវាយតម្លៃកម្រិតថ្នាក់រៀន ព្រោះវាយជួយកែលម្អការបង្រៀនរបស់ខ្ញុំ។ | | | | | | |
| 10.3 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនជាដំណើរការគួរឱ្យធុញទ្រាន់ និងធ្វើឱ្យខាតពេលក្នុងការបង្រៀន និងរៀន។ | | | | | | |
| 10.4 | ខ្ញុំយល់ថា មានការវាយតម្លៃជាច្រើនកំពុងអនុវត្តនៅក្នុងសាលារបស់ខ្ញុំ ដែលគួរតែកាត់បន្ថយខ្លះ។ | | | | | | |
| **សារៈសំខាន់នៃការវាយតម្លៃកម្រិតថ្នាក់រៀន** | | | | | | | |
| 10.5 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានសារៈប្រយោជន៍ជួយដល់ការសិក្សារបស់សិស្ស។ | | | | | | |
| 10.6 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀន អាចជួយឱ្យខ្ញុំប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយពីតម្រូវការរបស់សិស្ស។ | | | | | | |
| 10.7 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនអាចឱ្យខ្ញុំដឹងពីការវិវឌ្ឍការសិក្សារបស់សិស្សពីមួយថ្ងៃទៅមួយថ្ងៃ។ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 10.8 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីលើកទឹកចិត្តសិស្ស មិនមែនជាការដាក់ពិន័យនោះទេ។ | | | | | | |
| 10.9 | ខ្ញុំយល់ថា ការវាយតម្លៃកម្រិតថ្នាក់រៀនមានសារៈសំខាន់ណាស់ដែលអាចឱ្យគ្រូជួយសិស្សទាន់ពេលវេលា។ | | | | | | |
| 10.10 | ខ្ញុំយល់ថា ការវាយតម្លៃគ្មានសារៈប្រយោជន៍សម្រាប់ការបង្រៀនរបស់ខ្ញុំទេ។ | | | | | | |
| 10.11 | ខ្ញុំយល់ថា ការវាយតម្លៃធ្វើឱ្យសិស្សបាក់ទឹកចិត្ត និងបោះបង់ការសិក្សា។ | | | | | | |

## ២. យុទ្ធសាស្ត្រនៃការអនុវត្តការវាយតម្លៃកម្រិតថ្នាក់រៀន

***ការណែនាំ៖** ផ្នែកនេះមាន ២៨ សំណួរសម្រាប់គូស។ សូមពិចារណា ខ្លឹមសារសំណួរនីមួយៗដូចខាងក្រោម ហើយជ្រើសរើសយកចម្លើយដោយគូសសញ្ញា √ ទៅក្នុងចន្លោះតែមួយគត់ នៅក្នុងតារាងឱ្យត្រូវ**តាមការពិតជាក់ស្តែង** និង**តាមការអនុវត្តរបស់លោកគ្រូ អ្នកគ្រូ**។*

11. តើលោកគ្រូអ្នកគ្រូប្រើប្រាស់យុទ្ធសាស្ត្រវិធីអ្វីខ្លះ ក្នុងការវាយតម្លៃការសិក្សារបស់សិស្សកម្រិតថ្នាក់រៀន?

**[0 =មិនបានអនុវត្ត], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]**

| ល.រ | យុទ្ធសាស្ត្រវាយតម្លៃកម្រិតថ្នាក់រៀន | មិនបាន អនុវត្ត | បានអនុវត្ត (ក្នុងកម្រិតខាងក្រោម) | | | | |
|---|---|---|---|---|---|---|---|
| | | 0 | 1 | 2 | 3 | 4 | 5 |
| *ការវាយតម្លៃបញ្ចប់ប្រចាំខែ (ប្រឡងប្រចាំខែ)* | | | | | | | |
| 11.1 | និងគ្រូបង្រៀនមុខវិជ្ជាដូចគ្នាដ៏ទៃផ្សេងទៀត ធ្វើការវាយតម្លៃប្រចាំខែ ដោយប្រើប្រាស់វិញ្ញាសាតែមួយដូចគ្នា។ | | | | | | |
| 11.2 | និងគ្រូបង្រៀនមុខវិជ្ជាដូចគ្នាដ៏ទៃទៀត ធ្វើការវាយតម្លៃប្រចាំខែដោយប្រើប្រាស់វិញ្ញាសាផ្សេងគ្នា។ | | | | | | |
| 11.3 | នៅពេលរៀបចំវិញ្ញាសាប្រឡងប្រចាំខែ ខ្ញុំប្រើប្រាស់សៀវភៅកម្មវិធីសិក្សាគោល និងសៀវភៅកម្មវិធីសិក្សាលម្អិត ដែលរៀបរៀងដោយក្រសួងអប់រំ យុវជន និងកីឡា។ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11.4 | មុនពេលចាប់ផ្តើមតាក់តែងសំណួរតេស្ត ខ្ញុំតែងតែរៀបចំតារាងគម្រោងលម្អិតវិញ្ញាសាប្រឡងប្រចាំខែ។ | | | | | | |
| 11.5 | នៅពេលតាក់តែងសំណួរតេស្ត ខ្ញុំបានគិតដល់កម្រិតពុទ្ធិតាមទ្រឹស្តីបទប៊្លូម (Bloom´s Taxonomy) នៃសំណួរ ដូចជាកម្រិត ចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។ | | | | | | |
| 11.6 | ដើម្បីកំណត់ចំនួនសំណួរដែលត្រូវដាក់ក្នុងមួយវិញ្ញាសារ ខ្ញុំត្រូវគិតចេញពីរយៈពេលសរុបសម្រាប់ធ្វើមួយវិញ្ញាសា។ ដោយខ្ញុំបាន់ស្មានរយៈពេលសិស្សធ្វើសំណួរនីមួយៗ រួចបូកបញ្ចូលគ្នាស្មើនឹងរយៈពេលសរុប។ | | | | | | |
| 11.7 | ក្នុងមួយវិញ្ញាសា ខ្ញុំត្រូវតែធ្វើយ៉ាងឱ្យមានចំនួនសំណួរកម្រិតងាយតិច(20%) កម្រិតមធ្យមច្រើន (60%) និងកម្រិតលំបាកតិច (20%)។ | | | | | | |
| 11.8 | ក្នុងមួយវិញ្ញាសា ខ្ញុំប្រើប្រាស់ទម្រង់សំណួរសរសេរ (សិស្សសរសេរចម្លើយដោយខ្លួនពួកគេផ្ទាល់) ភាគច្រើនបំផុត។ | | | | | | |
| 11.9 | ខ្ញុំមិនប្រើប្រាស់ទម្រង់ពហុជ្រើសរើសដោយសារខ្ញុំមិនចេះពីរបៀបបង្កើតវា។ | | | | | | |
| 11.10 | ខ្ញុំមិនប្រើប្រាស់ទម្រង់ពហុជ្រើសរើសដោយសារទម្រង់សំណួរនេះមិនមានប្រើនៅក្នុងវិញ្ញាសារប្រឡងមធ្យមសិក្សាទុតិយភូមិ។ | | | | | | |
| **ការវាយតម្លៃបញ្ចប់មេរៀន ឬ ជំពូក** | | | | | | | |
| 11.11 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយមេរៀន ដោយប្រើប្រាស់សំណួរតេស្តផ្សេងៗ នៅក្នុងថ្នាក់រៀនដែលទាក់ទងនឹងមេរៀននោះ។ | | | | | | |
| 11.12 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយមេរៀន ដោយដាក់កិច្ចការផ្ទះជាលំហាត់ ឬ គម្រោងផ្សេងៗ ដែលទាក់ទងនឹងមេរៀននោះ។ | | | | | | |
| 11.13 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយជំពូក ដោយប្រើប្រាស់សំណួរ តេស្តផ្សេងៗ នៅក្នុងថ្នាក់រៀន ដែលទាក់ទងនឹងជំពូកនោះ។ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 11.14 | ខ្ញុំធ្វើការវាយតម្លៃចុងបញ្ចប់មួយជំពូក ដោយដាក់កិច្ចការផ្ទះ ជាលំហាត់ ឬ គម្រោងផ្សេងៗ ដែលទាក់ទងនឹងមេរៀន នោះ។ | | | | | | |
| *ការវាយតម្លៃជាប្រចាំ (គ្រប់ម៉ោងបង្រៀន)* | | | | | | | |
| 11.15 | ខ្ញុំសួរសំណួរផ្ទាត់មាត់ដើម្បីវាយតម្លៃនៅចុងបញ្ចប់ម៉ោង បង្រៀននីមួយៗ។ | | | | | | |
| 11.16 | ខ្ញុំដាក់លំហាត់ ឬ សំណួរឱ្យសិស្សឡើងធ្វើលើក្ដារខៀន ដើម្បីវាយតម្លៃនៅចុងបញ្ចប់ម៉ោងបង្រៀននីមួយៗ។ | | | | | | |
| 11.17 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សពិភាក្សាជាក្រុមតូចៗ (២ ទៅ ៥នាក់)។ | | | | | | |
| 11.18 | ខ្ញុំធ្វើការវាយតម្លៃដោយសម្ភាសសិស្ស ឬ ការសង្កេតមើល ការសម្ភាសរវាងសិស្សនិងសិស្ស។ | | | | | | |
| 11.19 | ខ្ញុំធ្វើការវាយតម្លៃដោយការសង្កេតមើលលើការចូលរួមផ្សេងៗ របស់សិស្ស នៅក្នុងដំណើរការរៀនសូត្រ។ | | | | | | |
| 11.20 | ខ្ញុំធ្វើការវាយតម្លៃដោយសង្កេតមើលអន្តរកម្មរវាងសិស្ស និង សិស្ស ព្រមទាំងរវាងសិស្ស និងគ្រូ ក្នុងថ្នាក់រៀន។ | | | | | | |
| 11.21 | ខ្ញុំធ្វើការវាយតម្លៃដោយផ្អែកលើគម្រោងស្រាវជ្រាវផ្សេងៗ។ | | | | | | |
| 11.22 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សបង្កើតជារូបភាពផ្សេងៗ។ | | | | | | |
| 11.23 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សធ្វើបទបង្ហាញផ្សេងៗ។ | | | | | | |
| 11.24 | ខ្ញុំធ្វើការវាយតម្លៃដោយប្រើប្រាស់វីដេអូ ឬសំឡេងផ្សេងៗ។ | | | | | | |
| 11.25 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សនិយាយសុន្ទរកថា ឬសេចក្ដី ថ្លែងការផ្សេងៗ។ | | | | | | |
| 11.26 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សធ្វើការពិសោធផ្សេងៗ។ | | | | | | |
| 11.27 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សសរសេររបាយការណ៍ផ្សេងៗ។ | | | | | | |
| 11.28 | ខ្ញុំធ្វើការវាយតម្លៃដោយឱ្យសិស្សធ្វើការជជែកវែកញែក និង ដេញដោលគ្នា។ | | | | | | |

## ៣. ការប្រើប្រាស់លទ្ធផលក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន

*ការណែនាំ៖ ផ្នែកនេះមាន ៩ សំណួរសម្រាប់គូស និងមានសំណួរសរសេរចំនួន ៣។ សូមពិចារណាខ្លឹមសារសំណួរនីមួយៗដូចខាងក្រោម ហើយជ្រើសរើសយកចម្លើយដោយគូសសញ្ញា √ ទៅក្នុងចន្លោះតែមួយគត់នៅក្នុងតារាងឱ្យត្រូវ**តាមការពិតជាក់ស្តែង** និង**តាមការអនុវត្តរបស់លោកគ្រូ អ្នកគ្រូ**។*

12. តើលោកគ្រូ អ្នកគ្រូប្រើប្រាស់លទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនក្នុងគោលបំណងអ្វី?

[0 = មិនបានអនុវត្ត], [1 = តិចតួចបំផុត 1 – 10%], [2 = តិចតួច 11 – 40%], [3 = មធ្យម 41 – 60%], [4 = ច្រើន 61 – 90%], [5 = ច្រើនបំផុត 91 – 100%]

| លរ | លទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀន | មិនបាន អនុវត្ត | បានអនុវត្ត (ក្នុងកម្រិតខាងក្រោម) | | | | |
|---|---|---|---|---|---|---|---|
| | | 0 | 1 | 2 | 3 | 4 | 5 |
| ***វិភាគលទ្ធផលនៃការវាយតម្លៃការសិក្សាសិស្សកម្រិតថ្នាក់រៀន*** | | | | | | | |
| 12.1 | ខ្ញុំវិភាគលទ្ធផលតាមសិស្សម្នាក់ៗ ដោយរកពិន្ទុសរុប និងមធ្យមភាគរបស់សិស្សម្នាក់ៗ។ | | | | | | |
| 12.2 | ខ្ញុំវិភាគលទ្ធផលតាមសំណួរនីមួយៗនិងរកភាគរយឆ្លើយត្រូវរបស់សំណួរនីមួយៗទាំងនោះ។ | | | | | | |
| 12.3 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីផ្តល់ព័ត៌មានត្រឡប់ឱ្យសិស្ស និងខ្លួនខ្ញុំផ្ទាល់។ | | | | | | |
| 12.4 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីវិភាគរកចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្សឱ្យបានជាក់លាក់។ | | | | | | |
| 12.5 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីបែងចែករកសិស្សខ្លាំង សិស្សមធ្យម និងសិស្សខ្សោយ។ | | | | | | |
| 12.6 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនទៅវិភាគដើម្បីកែលម្អវិធីសាស្ត្របង្រៀនរបស់ខ្ញុំ ក្នុងគោលបំណងជួយសិស្សខ្សោយ និងសិស្សមធ្យម។ | | | | | | |
| | | | | | | | |

| *បូកសរុបលទ្ធផលសិក្សាសិស្សក្នុងថ្នាក់រៀន* | | | | | | | |
|---|---|---|---|---|---|---|---|
| 12.7 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីបូកសរុបពិន្ទុប្រគល់ជូនសាលារៀន។ | | | | | | |
| 12.8 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃក្នុងថ្នាក់រៀនដើម្បីធ្វើចំណាត់ថ្នាក់ជ្រើសរើសសិស្សពូកែក្នុងថ្នាក់រៀន។ | | | | | | |
| 12.9 | ខ្ញុំយកលទ្ធផលនៃការវាយតម្លៃកម្រិតថ្នាក់រៀនដើម្បីធ្វើការប្រៀបធៀបលទ្ធផលរវាងថ្នាក់មួយនិងថ្នាក់មួយទៀត។ | | | | | | |

**សូមអរគុណចំពោះការយកចិត្តទុកដាក់ក្នុងការបំពេញកម្រងសំណួរនេះ**

*សូមលោកគ្រូ អ្នកគ្រូទទួលបានជោគជ័យ!*

## ឧបសម្ព័ន្ធទី ៣៖ Reliability

| Reliability Statistics | |
|---|---|
| Cronbach's Alpha | N of Items |
| .921 | 48 |

## ឧបសម្ព័ន្ធទី ៤៖ គណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៥៦២៩ អយក. ប្រក
(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh